ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន

## ការសិក្សាស្តីពី

## ការគាំទ្រគោលនយោបាយសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា

# សេចក្តីសង្ខេបនៃរបាយការណ៍បញ្ចប់

**ខែកុម្ភៈ ឆ្នាំ២០០៧**

ក្រុមសិក្សារបស់ JICA

វិទ្យាស្ថានស្រាវជ្រាវ NOMURA, LTD.

សាជីវកម្មអន្តរជាតិ KRI

# កថាមុខ

ក្នុងការឆ្លើយតបចំពោះសំណើសុំពីរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា រដ្ឋាភិបាលជប៉ុន បានសំរេចធ្វើការ សិក្សាស្តីពីកំណែលំអនៃគោលនយោបាយវិនិយោគ និងបានប្រគល់ការសិក្សានេះទៅឱ្យភ្នាក់ងារសហប្រតិបត្តិការ អន្តរជាតិជប៉ុន (ចៃកា)។

ចៃកា បានជ្រើសរើស និងបញ្ជូនក្រុមសិក្សាមួយ ដែលដឹកនាំដោយលោក សាកៃ ហ៊ីតូស៊ី នៃវិទ្យាស្ថានស្រាវជ្រាវ Nomura, LTD ពីខែធ្នូ ឆ្នាំ២០០៥ រហូតដល់ខែកុម្ភៈ ឆ្នាំ២០០៧។

ក្រុមសិក្សា បានជួបពិភាក្សាជាមួយមន្ត្រីពាក់ព័ន្ធនៃរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងធ្វើកិច្ចសម្ភាសន៍នៅក្នុងបរិវេណដែលពួកគេសិក្សា ព្រមទាំងនៅប្រទេសជិតខាង និងជប៉ុនផងដែរ។ ពេលវិលត្រឡប់មកជប៉ុនវិញ ក្រុមសិក្សា បានធ្វើការសិក្សាបន្ថែម ហើយរៀបចំរបាយការណ៍បញ្ចប់នេះ។

ខ្ញុំសង្ឃឹមថា របាយការណ៍នេះ នឹងរួមវិភាគទានក្នុងការជំរុញវិនិយោគចូលមកក្នុងប្រទេសកម្ពុជា និងដើម្បីពង្រឹងទំនាក់ទំនងមិត្តភាពរវាងប្រទេសយើងទាំងពីរ។

ជាអវសាន្ត ខ្ញុំសូមថ្លែងនូវអំណរគុណដ៏ជ្រាលជ្រៅ ចំពោះមន្ត្រីពាក់ព័ន្ធនៃរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សំរាប់កិច្ចសហប្រតិបត្តិការដ៏ជិតស្និទដែលមានចំពោះការសិក្សានេះ។

ខែ កុម្ភៈ ឆ្នាំ ២០០៧

អ៊ីហ្សាហ្វា តាដាស៊ី
អនុប្រធានរង
ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន

**របាយការណ៍បញ្ចប់**

ខែកុម្ភៈ ឆ្នាំ២០០៧

ជូនចំពោះលោក អ៊ីហ្សាហ្វា តាដាស៊ី

អនុប្រធានរង

ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន

ប្រធានបទ : លិខិតបញ្ជូន

សូមគោរពជូន

យើងខ្ញុំ មានសេចក្តីសោមនស្សរីករាយសូមដាក់ជូននូវរបាយការណ៍បញ្ចប់នៃ "ការសិក្សាស្តីពីការគាំទ្រគោលនយោបាយសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។ ការសិក្សានេះ ត្រូវបានប្រគល់ឱ្យវិទ្យាស្ថានស្រាវជ្រាវ NOMURA LTD សហការជាមួយនឹងសាជីវកម្មអន្តរជាតិ ក្រោមកិច្ចសន្យាជាមួយ ចៃកា។ របាយការណ៍ រួមមានសេចក្តីសង្ខេបប្រតិបត្តិ និងរបាយការណ៍ទាំងមូលជាភាសា "ជប៉ុន អង់គ្លេស និងខ្មែរ"។

ការសិក្សានេះ ត្រូវបានរៀបចំឡើងដើម្បីធ្វើការអង្កេតនូវបញ្ហាយល្អ និងបញ្ហាយអាក្រក់នៅប្រទេសកម្ពុជា ទាំងទិដ្ឋភាពម៉ាក្រូ និងមីក្រូ ដែលជាទិសដៅនៃការវិនិយោគដោយសហគ្រាសឯកជនបរទេស រាប់បញ្ចូលទាំងក្រុមហ៊ុនជប៉ុនផងដែរ ហើយព្រមទាំងរៀបចំជាយុទ្ធសាស្ត្រមួយ និងវិធានការនានា ដើម្បីពង្រីកការវិនិយោគពីជប៉ុន និងពីប្រទេសផ្សេងទៀត សំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា។ ការសិក្សានេះ នឹងគាំទ្រដល់ការកែលំអនៃគោលនយោបាយសេដ្ឋកិច្ចរបស់កម្ពុជា គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម និងគោលនយោបាយវិនិយោគ និងប្រត្យក្សកម្មនូវលទ្ធផលជាផ្លែផ្កាពីការនាំយកការវិនិយោគបរទេសផ្ទាល់ក្នុងពេលអនាគតដ៏ខ្លីនេះ។

ការសិក្សាដ៏ទូលំទូលាយដែលមានរយៈពេលខ្លីនេះ មិនមែនបានធ្វើឡើងដោយ "ចៃកា" នៅក្នុងប្រទេសអភិវឌ្ឍន៍ទេ។ ប៉ុន្តែ វាមានពេលវេលារួមមួយដែលមានកំរិតរវាង (១) ការរៀបចំយុទ្ធសាស្ត្រ វិធានការ និង(២) ផលិតនូវលទ្ធផលគួរជាទីពេញចិត្តក្នុងការពង្រីកការវិនិយោគផ្ទាល់ពីជប៉ុនក្នុងប្រទេសទាំងនោះ ហើយបន្តទៅការអភិវឌ្ឍន៍ឧស្សាហកម្ម នៃប្រទេស ដែលឆ្លៀតឱកាសនៃការវិនិយោគទាំងនោះ។ ដូច្នេះ វាជាប្រការចាំបាច់សំរាប់ភ្នាក់ងារអនុវត្តក្នុងប្រទេសអភិវឌ្ឍន៍ទាំងនោះ ដើម្បីធ្វើការខិតខំប្រឹងប្រែងឱ្យកាន់តែខ្លាំងឡើង ដើម្បីនឹងកែលំអបរិស្ថានធុរៈកិច្ច និងសំរាប់អង្គការជំនួយបរទេស ដើម្បីតាមដាន និងគាំទ្រចំពោះភ្នាក់ងារអនុវត្តន៍ទាំងនោះ ដើម្បីនឹងបញ្ជាក់ អំពីការប្រតិបត្តិដោយភ្នាក់ងារអនុវត្តនោះ។ វិធានការទាំងនេះ ជំរុញលើកទឹកចិត្តឱ្យមានការពង្រីកការវិនិយោគផ្ទាល់ពីជប៉ុន និងពីប្រទេសផ្សេងទៀត។ យោល

**របាយការណ៍បញ្ចប់**

ទៅតាមការអង្កេតតាមរយៈកិច្ចសម្ភាសន៍ដោយក្រុមសិក្សារបស់ចៃកា នៅប្រទេសជិតខាងរបស់កម្ពុជា ទិដ្ឋភាពអនាគត សំរាប់ការវិនិយោគជប៉ុនចូលក្នុងប្រទេសកម្ពុជា ក្នុងផ្នែក កាត់ដេរ ការកែច្នៃម្ហូបអាហារ អេឡិកត្រូនិក ។ល។ បានក្លាយទៅជាមានសក្តានុពលកាន់តែខ្លាំងឡើង ហើយ ការវិនិយោគជប៉ុន នឹងកើនឡើងជាលំដាប់នៅក្នុងប្រទេសកម្ពុជា ។

យើងខ្ញុំ សូមឆ្លៀតឱកាសនេះ ថ្លែងនូវកតវេទិតាដ៏ជ្រាលជ្រៅចំពោះចៃកា និងគណៈកម្មាធិការគាំទ្រជប៉ុន ដែលបានរៀបចំដោយចៃកា សំរាប់ផ្តល់ការណែនាំ ដើម្បីអនុវត្តនូវការសិក្សានេះ។ យើងខ្ញុំ សូមថ្លែងនូវការដឹងគុណផងដែរ ចំពោះកិច្ចសហប្រតិបត្តិការ និងការជួយជ្រោមជ្រែងពីសហភាគីដែលដឹកនាំដោយ ក.អ.ក/គ.វ.ក ក្នុងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ការិយាល័យនៅកម្ពុជារបស់ចៃកា ស្ថានទូតជប៉ុននៅកម្ពុជា និងកិច្ចសហការនៃអ្នកផ្តល់ជំនួយអន្តរជាតិ ដែលមានតំណាងនៅកម្ពុជា ដោយបានរួមចំណែកក្នុងគោលដៅដូចគ្នាក្នុងការកែលំអបរិស្ថានវិនិយោគនៃកម្ពុជា។

ដោយសេចក្តីគោរពដ៏ស្មោះស្ម័គ្របំផុត

សាកៃ ហ៊ីតូហ្ស៊ី

ប្រធានក្រុមសិក្សារបស់ចៃកា

សំរាប់ការសិក្សាស្តីពីការគាំទ្រគោលនយោបាយសេដ្ឋកិច្ចនៅកម្ពុជា

# មាតិការឿង


១. សេចក្តីផ្តើម ២
២. រចនាសម្ព័ន្ធរបាយការណ៍នៃការសិក្សា ២
២.១ បញ្ហាគោលនយោបាយ ៥
២.១.១ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ៥
២.១.២ ផលិតផលនាំចេញសក្តានុពល អមដោយការប្រែប្រួលក្នុងរចនាសម្ព័ន្ធឧស្សាហកម្ម និងពាណិជ្ជកម្ម ៧
២.១.៣ យុទ្ធសាស្ត្រឧស្សាហកម្ម ៨
២.១.៤ ឧស្សាហកម្មដែលមានភាពប្រជែងឈ្នះជាមួយនឹងទស្សនៈអនាគត ៩
(១) ឧស្សាហកម្មកាត់ដេរ ១០
(២) ឧស្សាហកម្មកែច្នៃម្ហូបអាហារ ជលផល និងកសិផល ១១
(៣) ឧស្សាហកម្មផលិតស្បែកជើង ១៣
(៤) ឧស្សាហកម្មគ្រឿងអគ្គីសនី/អេឡិកត្រូនិក ១៦
(៥) ឧស្សាហកម្មគ្រឿងម៉ាស៊ីន ១៨
២.២ បញ្ហាស្ថាប័ន ២០
២.២.១ វិធានការសំរាប់កែលំអក្របខ័ណ្ឌច្បាប់ ២០
២.២.២ វិធានការសំរាប់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម ២១
២.៣ បញ្ហាការចាត់ចែងការងារ ២៤
២.៣.១ ការអភិវឌ្ឍន៍ការចាត់ចែងការងារ ២៥
២.៣.២ ការជំរុញវិនិយោគ និងការធ្វើបណ្តាញពត៌មានវិនិយោគ ២៥
២.៣.៣ កាលវិភាគនៃការអនុវត្តន៍នូវការស្នើឡើងជាអនុសាសន៍ ២៧
២.៤ ផែនការសកម្មភាព និងគម្រោងការនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ២៨
២.៤.១ គម្រោងការនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ៣០

# របាយការណ៍សង្ខេប

## ១. សេចក្តីផ្តើម

ក្នុងចំណោមប្រទេសក្នុងមហាអនុតំបន់មេគង្គ ប្រទេសកម្ពុជា មានសក្តានុពលក្នុងការលូតលាស់ជាច្រើន និងបានក្លាយជាប្រទេសគួរជាទីចាប់អារម្មណ៍ពីសំណាក់វិនិយោគិនបរទេសលើកលែងតែក្រុមហ៊ុនជប៉ុន។ កត្តាខាងក្នុងវិជ្ជមានទាំងអស់ បាននឹងកំពុងតែមានឥទ្ធិពលលើការសំរេចចិត្តរបស់វិនិយោគិនបរទេសក្នុងការវិនិយោគ ឬប្តូរទីតាំងឧស្សាហកម្មមកកាន់កម្ពុជានោះ រួមមាន : ការស្តាបនាឡើងវិញប្រកបដោយជោគជ័យនូវសេដ្ឋកិច្ច និងស្ថេរភាពនយោបាយ ភាពសំបូរបែបនៃពលកម្ម ជាមួយនឹងកំរិតគុណភាពសមរម្យ ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលឆ្ពោះ ទៅរកការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ល។ ហើយកត្តាអនុគ្រោះខាងក្រៅដូចជា : ការកើនតម្លៃពលកម្មនៅប្រទេសជិតខាង ការដាក់វិធានការ Anti-Dumping របស់សហរដ្ឋអាមេរិក និងអឺរ៉ុប ចំពោះចិន និងវៀតណាម បរិស្ថានវិនិយោគ របស់ចិនកាន់តែអាក្រក់ទៅៗចំពោះឧស្សាហកម្មអតិពលកម្ម ។ល។

ប៉ុន្តែកត្តាមួយចំនួនបានធ្វើឱ្យមានការរាំងស្ទះដល់ភាពប្រជែងឈ្នះនៃឧស្សាហកម្មសក្តានុពលនៅតែកើតមានឡើងនៅកម្ពុជា។ វិធានការប្រកបដោយប្រសិទ្ធភាព គួរតែត្រូវបានលើកយកមកអនុវត្តន៍ដើម្បីកែលំអកត្តារាំងទាំងនេះ ដើម្បីនឹងធ្វើឱ្យប្រសើរឡើងនូវបរិស្ថានវិនិយោគកម្ពុជា។ ការកែលំអបរិស្ថានវិនិយោគនៅកម្ពុជា នឹងទាក់ទាញបានកាន់តែច្រើននូវការវិនិយោគបរទេសផ្ទាល់។ នៅខែកញ្ញាឆ្នាំ២០០៤ រដ្ឋាភិបាលកម្ពុជា បានស្នើសុំការគាំទ្រពីរដ្ឋាភិបាលជប៉ុន ដោយយល់ឃើញថានឹងសំរេចបាននូវកំណើននៃការវិនិយោគបរទេសផ្ទាល់សំខាន់ពីជប៉ុន។ នៅខែសីហា ឆ្នាំ២០០៥ រដ្ឋាភិបាលទាំងពីរ បានឯកភាពក្នុងការអនុវត្តការសិក្សាស្តីពីការគាំទ្រគោលនយោបាយសេដ្ឋកិច្ចនៅកម្ពុជា ដោយបានចាត់តាំងភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ឱ្យអង្កេតកាលានុវត្តន៍ភាព និងបញ្ហាប្រឈមរបស់កម្ពុជា ទាំងទិដ្ឋភាពម៉ាក្រូ និងមីក្រូ ដែលជាគោលដៅវិនិយោគដោយសហគ្រាសឯកជនបរទេស រួមទាំងក្រុមហ៊ុនជប៉ុន ព្រមទាំងរៀបចំយុទ្ធសាស្ត្រ និងវិធានការដើម្បីពង្រីកការវិនិយោគពីជប៉ុន និងកន្លែងផ្សេងទៀតសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មនៅកម្ពុជា។ ការសិក្សានេះមានគោលដៅចំបងដើម្បីអភិវឌ្ឍន៍បរិស្ថានវិនិយោគដែលអនុគ្រោះនៅកម្ពុជា ហើយការសិក្សានេះ នឹងរួមចំណែកក្នុងការជំរុញវិនិយោគបរទេសផ្ទាល់មកកម្ពុជា។ កម្ពុជា បាននឹងកំពុងកែលំអប្រព័ន្ធរបស់ខ្លួនផ្អែកលើបទដ្ឋានអន្តរជាតិ មាន : ILO, WTO ។ល។ ប៉ុន្តែ ដើម្បីនឹងនាំយកវិនិយោគជប៉ុន កម្ពុជា ត្រូវតែទទួលយកប្រព័ន្ធផលិតកម្មរបស់ជប៉ុន។

## ២. រចនាសម្ព័ន្ធរបាយការណ៍នៃការសិក្សា

របាយការណ៍ ផ្តោតលើចំណុចសំខាន់ៗជាចំបងចំនួន៤ ដែលត្រូវទាក់ទងទៅ :

- បញ្ហាគោលនយោបាយ
- បញ្ហាស្ថាប័ន

- បញ្ហានៃការចាត់ចែងការងារ
- ផែនការសកម្មភាព និងគម្រោងការនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច

បញ្ហាទាំងនេះ នឹងត្រូវបង្ហាញដោយចែកចេញជាពីរផ្នែក ក្នុងនោះផ្នែកទី ១ គឺពាក់ព័ន្ធជាចំបងជាមួយនឹងបញ្ហាគោលនយោបាយ ដែលរាប់បញ្ចូលទាំងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងយុទ្ធសាស្ត្រឧស្សាហកម្ម។ ជ្រើសរើសនូវឧស្សាហកម្ម/ផលិតផលមានស្រាប់ ដែលមានភាពប្រជែងឈ្នះ ជាមួយនឹងទិដ្ឋភាពអនាគតរបស់វា។ កំណត់កត្តារាំងស្ទះដល់ភាពប្រជែងឈ្នះ។ គោលនយោបាយ និងយុទ្ធសាស្ត្រសមស្របសំរាប់អភិវឌ្ឍន៍ឧស្សាហកម្មទាំងនេះ ត្រូវបានស្នើឡើងជាអនុសាសន៍។

ផ្នែកទី ២ នៃរបាយការណ៍នេះ គឺពាក់ព័ន្ធជាមួយបញ្ហាស្ថាប័ន និងបញ្ហានៃការចាត់ចែងការងារ។ ផ្នែកនេះ ផ្តោតជាសំខាន់លើការជំរុញវិនិយោគ។ អនុសាសន៍ពាក់ព័ន្ធទៅនឹងរបៀបកែលំអច្បាប់ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ដទៃទៀត និងការធ្វើឱ្យប្រសើរឡើងនូវមុខងារជំរុញការវិនិយោគរបស់ ក.អ.ក "គ.វ.ក" ត្រូវបានផ្តល់ជាមួយទស្សនៈដើម្បីអភិវឌ្ឍន៍បរិស្ថានវិនិយោគប្រកបដោយភាពអនុគ្រោះនៅកម្ពុជា។ ផែនការសកម្មភាព និងអាទិភាពវូបនីយកម្មនៃគម្រោងការនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចសំរាប់ការអភិវឌ្ឍន៍នៃការចាត់ចែងសំខាន់ៗ ត្រូវបានធ្វើជាស្ថាបពរនៅក្នុងផ្នែកនេះ។

គំនូសបំព្រួញស្តីពីរចនាសម្ព័ន្ធនៃមាតិកានៃការសិក្សា អាចត្រូវពិពណ៌នាដូចខាងក្រោម ៖

## រូបទី ១ គំនូសបំព្រួញស្តីពីរចនាសម្ព័ន្ធនៃមាតិកានៃការសិក្សា



## ២.១ បញ្ហាគោលនយោបាយ

បញ្ហាគោលនយោបាយ គ្របដណ្តប់លើគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងយុទ្ធសាស្ត្រឧស្សាហកម្ម តំរូវឱ្យមានការអភិវឌ្ឍន៍សេដ្ឋកិច្ច និងឧស្សាហកម្មកម្ពុជា។ ផ្អែកលើការវិភាគស្តីពីភាពប្រជែងឈ្នះនៃឧស្សាហកម្ម និងការនាំចេញ ការអង្កេតដោយការសម្ភាសន៍ និងកំរងសំណួរ ក្រុមសិក្សា បានជ្រើសរើសយកឧស្សាហកម្មចំនួន ៥ មកវិភាគ។ ការផ្តោតត្រូវបានដាក់លើការអភិវឌ្ឍន៍នៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងយុទ្ធសាស្ត្រឧស្សាហកម្ម ពាក់ព័ន្ធទៅនឹងឧស្សាហកម្មកម្ពុជា មានទស្សនវិស័យអនាគតសក្តានុពល រួមមានៈ ឧស្សាហកម្មកាត់ដេរ ឧស្សាហកម្មកែច្នៃម្ហូបអាហារ ជលផល និងកសិផល ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មផលិតគ្រឿងអគ្គិសនី/អេឡិកត្រូនិក និងឧស្សាហកម្មគ្រឿងម៉ាស៊ីន។

អនុសាសន៍ជាយុទ្ធសាស្ត្រសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មទាំងនេះ ត្រូវបានផ្តល់ដោយសារតែឧស្សាហកម្មទាំងនេះ ត្រូវបានដឹងថាជាឧស្សាហកម្មដែលមានសក្តានុពលនាពេលអនាគត។ កម្ពុជា មានភាពប្រជែងឈ្នះកំរិតខ្ពស់ក្នុងឧស្សាហកម្មកាត់ដេរ ខណៈដែលមានសក្តានុពលជាច្រើនទៀតសំរាប់ឧស្សាហកម្មផលិតស្បែកជើង ឧស្សាហកម្មកែច្នៃម្ហូបអាហារ ជលផល និងកសិផល ដើម្បីរីកចំរើនក្នុងរយៈពេលមធ្យម និងទិដ្ឋភាពអនាគតសំរាប់ការអភិវឌ្ឍន៍នៃឧស្សាហកម្មផលិតគ្រឿងអគ្គិសនី/អេឡិកត្រូនិក និងឧស្សាហកម្មគ្រឿងម៉ាស៊ីន ក្នុងរយៈពេលវែង។

### ២.១.១ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

ផ្នែកនេះ ពាក់ព័ន្ធជាសំខាន់ជាមួយការកំណត់កំលាំងចលករសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា។ កត្តាសំខាន់ៗដែលត្រូវបានគិតទុកថាមានឥទ្ធិពលទៅលើការអភិវឌ្ឍន៍ឧស្សាហកម្មរបស់កម្ពុជា គឺ : និន្នាការឆ្ពោះឡើងនៃការវិនិយោគបរទេសផ្ទាល់ទៅក្នុងឧស្សាហកម្មកាត់ដេរ ការប្រជែងឈ្នះជាមួយប្រទេសជិតខាង ព្រមទាំងផលិតកម្មប្រេង/ឧស្ម័ន។

កត្តាជាគន្លឹះផ្សេងទៀតដែលត្រូវបានរំពឹងទុកថាមានផលប៉ះពាល់ជាវិជ្ជមានលើអនាគតរបស់កម្ពុជា គឺត្រូវបានកំណត់ដូចជា ការកើនឡើងនូវប្រាក់បៀវត្សរ៍កម្មករនៃប្រទេសជិតខាង កំណើននៃប្រាក់ចំណូលរបស់កម្មករនៅប្រទេសជិតខាង ការកើនតម្លៃនៃប្រាក់យ៉ាន់ចិននៅឆ្នាំ២០០៩ បន្ទាប់ពីការលុបបំបាត់នូវវិធានការសុវត្ថិភាពចំពោះចិន ដោយសហរដ្ឋអាមេរិក និងអឺរ៉ុប ការលុបបំបាត់នូវកូតាសំរាប់ផលិតផលកាត់ដេរវៀតណាម ជាមួយនឹងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ការកាត់បន្ថយជាបណ្តើរៗចំពោះវិធានការ Anti-Dumping សំរាប់ការនាំចេញផលិតផលកាត់ដេរពីចិន ។ល។ និង។ល។ ការព្យាករណ៍តាមបរិមាណ នៃម៉ាក្រូសេដ្ឋកិច្ចកម្ពុជា និងអនុសាសន៍ជាគោលនយោបាយដើម្បីសំរេចបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចិរភាព ត្រូវ បានផ្តល់នៅក្នុងផ្នែកនេះផងដែរ។

ការព្យាករណ៍ជាស្ថិតិ បង្ហាញថា កំរិតបន្តនៃការវិនិយោគបរទេសផ្ទាល់ដែលមានសកម្មភាព កំណើនសេដ្ឋកិច្ចពី ៧ ទៅ ៩% ត្រូវបានរំពឹងទុកថានឹងទទួលបាននៅក្នុងឆ្នាំ២០១០បន្ទាប់ពីវាត្រូវបានគេរំពឹងទុកថាមានស្ថេរភាពរវាង ៦-៧%

រហូតដល់ឆ្នាំ ២០១២ ក្នុងអំឡុងពេលដែលកម្ពុជា មានបទពិសោធន៍ក្នុងអត្រាកំណើនខ្ពស់ជាច្រើន ពេលផលិតកម្មប្រេងចាប់ផ្តើម និងឈានដល់ដំណាក់កាលផលិតកម្មមានស្ថេរភាព។ ពេលនោះ វាត្រូវបានរំពឹងទុកថានឹងសំរេចបាននូវកំណើនថេរប្រមានជា ៦% ក្នុងរយៈពេលវែង។

ខណៈពេលដែលផលិតកម្ម និងការនាំចេញនៃផលិតផលកាត់ដេរប្រកួតប្រជែងនៃកម្ពុជា បន្តីរកចំរើននោះ អតិរេកពាណិជ្ជកម្ម ត្រូវបានរំពឹងថានឹងសំរេចបានជាសំខាន់លើវិស័យទេសចរណ៍ និងផលិតកម្មប្រេងបន្ទាប់ពីឆ្នាំ២០១២។ វិស័យសេវាកម្ម ត្រូវបានរំពឹងថាដើរតួនាទីដ៏សំខាន់ក្នុងការធ្វើឱ្យមានតុល្យភាពពាណិជ្ជកម្មប្រកបដោយលក្ខណៈអនុគ្រោះនៅពេលអនាគត។

ការវិនិយោគបរទេសផ្ទាល់ បានដើរតួយ៉ាងសំខាន់ ហើយនឹងបន្តដើរយ៉ាងសំខាន់សំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មប្រកួតប្រជែងដែលមានស្រាប់ (ឧ.ហ: ឧស្សាហកម្មកាត់ដេរ) និងវិស័យសក្តានុពលផ្សេងទៀត (ឧ.ហ: ឧស្សាហកម្មកែច្នៃម្ហូបអាហារ ជលផល និងកសិផល ឧស្សាហកម្មផលិតគ្រឿងអគ្គិសនី/អេឡិកត្រូនិក និងឧស្សាហកម្មគ្រឿងម៉ាស៊ីន)។ ដូច្នេះហើយ ការគូសបញ្ជាក់ដ៏ធំបំផុតនៅទីនេះ គួរតែត្រូវបានដាក់លើការបង្កើតវិធានាការជាគោលនយោបាយ និងយុទ្ធសាស្ត្រ ដើម្បីទាក់ទាញការវិនិយោគបរទេសផ្ទាល់ និងដើម្បីគៀងគរវិនិយោគក្នុងស្រុក នៅក្នុងឧស្សាហកម្មសក្តានុពលទាំងនេះ។

ដើម្បីនឹងរក្សាបាននូវកំលាំងចលករថេរនៃលំហូរចូលរបស់ការវិនិយោគបរទេសផ្ទាល់គោលនយោបាយជាមូលដ្ឋានដើម្បីត្រួតពិនិត្យអតិផរណា និងដើម្បីធ្វើឱ្យមានស្ថេរភាពនៃការប្រែប្រួលរបស់រូបិយវត្ថុ គឺជាប្រការសំខាន់បំផុត។ លើសពីនេះទៅទៀត រដ្ឋាភិបាលកម្ពុជា គួរតែប្តេជ្ញា ពង្រឹងកិច្ចខិតខំប្រឹងប្រែងជាបន្តរបស់ខ្លួនដើម្បីធ្វើសេរីភាវូបនីយកម្ម ទីផ្សារ ទទួលយកនូវគោលនយោបាយសារពើពន្ធយ៉ាងប្រយ័ត្នប្រយែងបំផុតមួយ និងដើម្បីធ្វើពិពិធកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ច។

រចនាសម្ព័ន្ធចំបងនៃផ្នែកនេះ អាចត្រូវពិពណ៌នាក្នុងរូបខាងក្រោម :

| | | | | |
|---|---|---|---|---|
| ការកំណត់កត្តាដែលជះឥទ្ធិពលលើម៉ាក្រូសេដ្ឋកិច្ចកម្ពុជា | ⇨ | ការព្យាករណ៍ជាបរិមាណនៃម៉ាក្រូសេដ្ឋកិច្ចកម្ពុជា | ⇨ | អនុសាសន៍ដើម្បីសំរេចបាននូវកំណើនសេដ្ឋកិច្ចចីរភាព |

### ២.១.២ ផលិតផលនាំចេញសក្តានុពល អមដោយការប្រែប្រួលក្នុងរចនាសម្ព័ន្ធឧស្សាហកម្ម និងពាណិជ្ជកម្ម

ជាបឋម ផ្នែកនេះចាប់ផ្តើមជាមួយនឹងការជ្រើសរើសផលិតផលប្រកួតប្រជែងសំរាប់ការនាំចេញ។ វាកំណត់ជាសំខាន់នូវមុខទំនិញនៃការនាំចេញសំខាន់ៗដែលមានសក្តានុពលជាមួយនឹងការប្រែប្រួលរចនាសម្ព័ន្ធពាណិជ្ជកម្ម និងឧស្សាហកម្ម។ ការសិក្សា បានធ្វើការវិភាគយ៉ាងទូលំទូលាយលើថាមភាព (dynamics) នៃការបង្ហាញឧត្តមភាពប្រៀបធៀបរបស់កម្ពុជាលើផលិតផលនាំចេញផ្សេងគ្នា។ ការវិភាគលើឧត្តមភាពប្រៀបធៀបបានបង្ហាញថាកម្ពុជាមានឧត្តមភាពប្រៀប

ធៀបខ្ពស់ក្នុងផលិតផលកាត់ដេរ ស្បែកជើង សាច់ត្រីបង្កក សត្វវិន្តជាតិ (crustacean) (បង្កង ក្តាម) និងដំឡូងឈើ។ ភាពប្រជែងឈ្នះរបស់កម្ពុជាក្នុងវិស័យដូងប្រេង ការផលិតបំណែក/បរិក្ខាអគ្គិសនីរថយន្ត និងបំណែក/សំភារៈបរិក្ខារសំរាប់យានយន្ត នឹងបានរឹងមាំក្នុងរយៈពេលវែង។ វាត្រូវបានរំពឹងថា និន្នាការនៃភាពប្រជែងឈ្នះនៅក្នុងផ្នែកសាច់ត្រីបង្កក នឹងបានទទួលភ្លាមៗ ខណៈពេលដែលផលិតផលកាត់ដេរ នឹងស្ថិតនៅក្នុងស្ថេរភាពក្នុងអនាគតដែលមិនអាចមើលឃើញ។ ហេតុនេះ ផលិតផលកាត់ដេរនឹងដើរតួនាទីសំខាន់ជាប្រភេទមុខទំនិញនាំចេញសំខាន់ ហើយផលិតផលស្បែកជើង និងផលិតផលកសិកម្មកែច្នៃ ជាពិសេស ដំឡូងឈើ/ដំឡូងមី និងផលិតផលជលផលប្រពលវប្បកម្មសមុទ្រ មានសក្តានុពលក្នុងការនាំចេញយ៉ាងសំខាន់។

ដោយធ្វើការវិភាគពីភាពប្រជែងឈ្នះនាអនាគតនៃផលិតផលដែលបានរៀបរាប់ខាងលើសំរាប់ការនាំចេញ វាត្រូវបានគេប៉ាន់ស្មានថាការនាំចេញផលិតផលកាត់ដេរ នឹងនៅតែកាន់កាប់ច្រើនជាង ៥០%នៃតម្លៃនាំចេញសរុបសំរាប់ប៉ុន្មានឆ្នាំខាងមុខ។ អត្រានេះ ត្រូវបានរំពឹងថានឹងថយចុះនៅឆ្នាំ២០១០ ប៉ុន្តែផលិតផលផ្សេងទៀត នឹងបន្តកើនឡើងជាលំដាប់។ ពាក់ព័ន្ធនឹងផលិតផលស្បែកជើង ការនាំចេញរបស់វា ត្រូវបានប៉ាន់ស្មានថានឹងកើនឡើង ហើយចំណែកនៅក្នុងតម្លៃនាំចេញសរុបរបស់កម្ពុជា នឹងកើនដល់ ៤% ក្នុងឆ្នាំ ២០១០ និង ៦% នៅឆ្នាំ២០២០។ ផលិតផលស្បែកជើង និងកាត់ដេរ នឹងជាផលិតផលប្រកួតប្រជែងដ៏សំខាន់របស់កម្ពុជា ក្នុងការនាំចេញនាពេលអនាគត។

កំណើនក្នុងការនាំចេញនៃសាច់ត្រីបង្កក និងផលិតផលសត្វវិន្តជាតិ ត្រូវបានរំពឹងថានឹងកើនឡើងដែរ។ ទោះជាយ៉ាងណា ផលិតផលទាំងនេះ នឹងក្លាយទៅជាផលិតផលប្រកួតប្រជែងក្នុងទីផ្សារអន្តរជាតិ ដោយផ្អែកលើវិធានការជាគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញឧស្សាហកម្មនេះ។ ទាក់ទិនទៅនឹងផលិតផលដូងប្រេង និងដំឡូងមី កំណើនជាលំដាប់នៃការនាំចេញ ត្រូវបានគ្រោងទុកជាមុន។ ជាថ្មីម្តងទៀត ក៏វិតនៃការរីកចំរើន ផ្អែកជាសំខាន់ទៅលើក៏វិតនៃបច្ចេកវិទ្យាកែច្នៃ ដែលបំពាក់ឱ្យកម្ពុជា។

ក្នុងឧស្សាហកម្មអេឡិកត្រូនិក វាត្រូវបានរំពឹងថានឹងប្រើរយៈពេលយូរបន្តិចដើម្បីមានឧស្សាហកម្មបែបនេះឱ្យមានការអភិវឌ្ឍន៍ពេញលេញ។ តាំងពីកម្ពុជា បានមកដល់ដំណាក់កាលរីកចំរើនដំបូងនៃការអភិវឌ្ឍន៍ផលិតផលដំបូងក្នុងឧស្សាហកម្មនេះ ផលិតកម្មនៃផលិតផលអតិពលកម្មដូចជា ការរំដុំភ្លើង ខ្សែភ្លើង និងប្រព័ន្ធខ្សែភ្លើងរថយន្ត (wire harness) នឹងជាសក្តានុពល។

កម្ពុជាត្រូវសំរេចឱ្យបាននូវភាពប្រជែងឈ្នះក្នុងផលិតផលស្បែកជើង និងកាត់ដេរ ផលិតផលជលផលសមុទ្រ និងកសិផល សំរាប់ការនាំចេញ។ វាអាចទៅរួច ក្នុងរយៈពេលវែងសំរាប់ឧស្សាហកម្មគ្រឿងបន្សំអេឡិកត្រូនិក និងគ្រឿងម៉ាស៊ីន ដែលនឹងត្រូវបានបង្កើតឡើង និងលូតលាស់ជាមួយនឹងការកែលំអបរិស្ថានវិនិយោគនៅកម្ពុជា។

ការវិភាគ នៃភាពប្រជែងឈ្នះនាពេលអនាគតរបស់កម្ពុជានៅក្នុងផលិតផលដែលបានរៀបរាប់ខាងលើ តាមរយៈថាមភាពនៃសន្ទស្សន៍ឧត្តមភាពប្រៀបធៀប ដែលកម្ពុជា ត្រូវបានរំពឹងថានឹងបាត់បង់ភាពប្រជែងឈ្នះក្នុងផលិតផលកាត់ដេរ ហើយទទួលបានមកវិញក្នុងផលិតផលស្បែកជើង។ ការថយចុះ ក្នុងភាពប្រជែងឈ្នះរបស់វានៃជំឡូងមី សត្វវន្តជាតិ និងសាច់ត្រីបង្កក ត្រូវបានប៉ាន់ស្មាន។ ឧស្សាហកម្មប្រេងដូងរឹងមាំរបស់ម៉ាឡេស៊ី និងឥណ្ឌូនេស៊ី អាចមានផលប៉ះពាល់អវិជ្ជមានខ្លះលើភាពប្រជែងឈ្នះរបស់កម្ពុជាក្នុងផលិតផលនេះ។ ទាក់ទិនទៅនឹង ផលិតផលគ្រឿងម៉ាស៊ីន និងអេឡិកត្រូនិកមានភាពប្រជែងឈ្នះដែលមាននិន្នាការកើនឡើងតែបន្តិចបន្តួចប៉ុណ្ណោះ អាចត្រូវបានគេព្យាករណ៍ទុកបាន។

ក្នុងចំណោមផលិតផលប្រកួតប្រជែងសក្តានុពលជាមួយនឹងទស្សនអនាគតសំរាប់ការនាំចេញ ភាពប្រជែងឈ្នះរបស់កម្ពុជាក្នុងផលិតផលស្បែកជើង និងកាត់ដេរ ត្រូវបានរំពឹងទុកថានឹងមានកំរិតខ្ពស់បំផុតនាពេលអនាគត ហើយទាំងនេះអាចត្រូវបានតំរាប់តាមដោយផលិតផលកែច្នៃផលសមុទ្រ និងកសិផល។ ទោះបីថាកម្ពុជាមិនត្រូវបានរំពឹងថានឹងមានការប្រកួតប្រជែងក្នុងផលិតផលគ្រឿងម៉ាស៊ីន និងអេឡិកត្រូនិកនាពេលអនាគតក៏ដោយ វិធានការជាគោលនយោបាយ ដើម្បីអភិវឌ្ឍន៍ឧស្សាហកម្មទាំងនេះ គួរតែមិនត្រូវបានប្រងើយកន្តើយឡើយ ព្រោះថាការអភិវឌ្ឍន៍ឧស្សាហកម្មទាំងនេះ នឹងត្រូវដើរតួយ៉ាងសំខាន់ក្នុងការធ្វើឱ្យសេដ្ឋកិច្ចរបស់កម្ពុជាជឿនលឿន នៅពេលដែលមានការប្រែប្រួលក្នុងវដ្តជីវិតនៃឧស្សាហកម្មនាពេលអនាគត។

**២.១.៣ គោលនយោបាយឧស្សាហកម្ម**

ផ្នែកនេះ បង្ហាញជាសំខាន់នូវទស្សនៈទូទៅនៃគោលនយោបាយឧស្សាហកម្ម ជាមួយនឹងការផ្តោតលើវិស័យកម្មន្តសាល ដែលជាផ្នែកមួយនៃគំរោងសិក្សានេះ។ នៅទីនេះ វាក្យស័ព្ទ "គោលនយោបាយឧស្សាហកម្ម" ត្រូវបានប្រើប្រាស់ក្នុងអត្ថន័យយ៉ាងទូលំទូលាយនៃគោលនយោបាយសំរាប់ការពង្រីកនៃការផលិត ដើម្បីរួមវិភាគទានដល់ការលូតលាស់នៃសេដ្ឋកិច្ចរបស់កម្ពុជា។ ក្នុងបច្ចុប្បន្ន វិស័យឧស្សាហកម្មកម្មន្តសាល បាននឹងកំពុងអភិវឌ្ឍន៍នៅកម្ពុជា ត្រូវបានកំរិតកំណត់យ៉ាងខ្លាំង (ជាសំខាន់ ចំពោះឧស្សាហកម្មកាត់ដេរ) ក្នុងន័យប្រកដប្រជានេះ ផ្នែកគោលនយោបាយសំរាប់ការសិក្សាជាអាទិភាពគឺមាន៤ចំនុចដូចតទៅ : (១) ការទទួលបាននូវមូលធន និងបច្ចេកវិទ្យាតាមរយៈការទាក់ទាញការវិនិយោគបរទេសផ្ទាល់ (២) លក្ខខណ្ឌនៃហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មត្រូវការជាចាំបាច់ដើម្បីទាក់ទាញការវិនិយោគបរទេសផ្ទាល់ (៣) ការអភិវឌ្ឍន៍ធនធានមនុស្ស និង (៤) វិធានការជាក់លាក់សំរាប់ការជំរុញឧស្សាហកម្មទាក់ទាញ។ រាជរដ្ឋាភិបាលកម្ពុជា មិនទាន់មានបទពិសោធន៍ បុគ្គលិក អង្គការចាត់តាំង និងចំណេះធ្វើគ្រប់គ្រាន់នៅឡើយទេក្នុងពេលបច្ចុប្បន្ននេះ ដូច្នេះហើយ ត្រូវតែធ្វើសកម្មភាពឱ្យបានទាន់ពេល និងសមស្របណាមួយអមដោយជំនួយបច្ចេកទេសពីប្រទេសដទៃទៀត។

គំរោងនេះ បានជ្រើសយកឧស្សាហកម្មកម្មន្តសាលចំនួន ៥ ជាឧស្សាហកម្មសន្យា សំរាប់ការអភិវឌ្ឍន៍កម្ពុជា (ឧ.ហ កាត់ដេរ កែច្នៃម្ហូបអាហារ ស្បែកជើង និងការតម្លើងធម្មតានៃគ្រឿងម៉ាស៊ីន និងគ្រឿងបរិក្ខាអគ្គិសនី និងអេឡិកត្រូ

និក។ ផ្នែកខាងក្រោយនេះ បង្ហាញពីការត្រួតពិនិត្យលំអិត និងអនុសាសន៍សំរាប់គ្រប់វិស័យ ដូចមានពាក់ព័ន្ធនឹងគោលនយោបាយ ដើម្បីគៀងគរមូលធនបរទេស និងជំរុញឧស្សាហកម្ម រួមមានវិធានការដើម្បីទាក់ទាញការវិនិយោគបរទេសផ្ទាល់ និងជំរុញការនាំចេញ។ តារាងខាងក្រោម បង្ហាញពីការភ្ជាប់គ្នារវាងឧស្សាហកម្មសន្យា និងគោលនយោបាយឧស្សាហកម្ម។

**តារាងទី ១ ការភ្ជាប់គ្នារវាងឧស្សាហកម្មសក្តានុពល និងគោលនយោបាយឧស្សាហកម្ម**

| វិស័យសក្តានុពល | គោលនយោបាយទាក់ទាញ FDI | គោលនយោបាយដែលមានលក្ខខណ្ឌជាហេដ្ឋារចនាសម្ព័ន្ធ | គោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្ស | គោលនយោបាយជំរុញឧស្សាហកម្ម (ការស្ថាបនាចក្ខុវិស័យមួយ) |
|---|---|---|---|---|
| កាត់ដេរ | △ | △ | ○ | ចាំបាច់ |
| កសិកម្ម នេសាទ និងកែច្នៃម្ហូបអាហារ | ○ | ◎ | ◎ | ចាំបាច់ |
| កែច្នៃម្ហូបអាហារ | ○ | ◎ | ◎ | ចាំបាច់ |
| ស្បែកជើង | ○ | ○ | ○ | ចាំបាច់ |
| ការតម្លើងធម្មតានៃគ្រឿងអគ្គិសនី/អេឡិកត្រូនិក | ◎ | ◎ | ◎ | ឆាប់ពេក |
| គ្រឿងអគ្គិសនី/អេឡិកត្រូនិក (ការតម្លើធម្មតា) | ◎ | ◎ | ◎ | ឆាប់ពេក |
| គ្រឿងម៉ាស៊ីនធម្មតា | ◎ | ◎ | ◎ | ឆាប់ពេក |

កំណត់សំគាល់ : ◎=ចាំបាច់បំផុត ○=ចាំបាច់ △= ដោះស្រាយរួចរាល់ហើយ

ប្រភព : ក្រុមសិក្សារបស់ JICA

## ២.១.៤ ឧស្សាហកម្មប្រកួតប្រជែងជាមួយទិដ្ឋភាពអនាគត

ក្នុងវិស័យឧស្សាហកម្មទាំង ៥ ដែលរំពឹងថានឹងមានកំណើនក្នុងពេលអនាគត គេបានវិភាគស្ថានភាពបច្ចុប្បន្ន និងបរិស្ថានប្រកួតប្រជែងអំពីវិស័យនីមួយៗ ហើយគេបានជីកកកាយរកនូវគុណសម្បត្តិ និងកំហុសឆ្គងដែលកម្ពុជាមាន។ លើសពីនេះទៅទៀត គោលនយោបាយ ដែលបានសើរើឡើងវិញ គឺជាសេចក្តីត្រូវការចាំបាច់ក្នុងពេលអនាគត ហើយគេបានរកឃើញនូវបញ្ហាជាក់លាក់។ ជាលទ្ធផល អ្វីដែលជាសេចក្តីត្រូវការដើម្បីបំរើឱ្យបាននូវបរិស្ថានសំរាប់ទាក់ទាញមូលធនបរទេស គឺត្រូវបានសឱ្យឃើញដូចតទៅ :

(១) **ឧស្សាហកម្មកាត់ដេរ :** នាពេលបច្ចុប្បន្ននេះ ឧស្សាហកម្មសំខាន់មួយក្នុងចំណោមឧស្សាហកម្មសំខាន់ៗដទៃទៀតនៅកម្ពុជា គឺជាឧស្សាហកម្មកាត់ដេរ។ ឧស្សាហកម្មនេះ កំពុងតែពឹងផ្អែកលើពលកម្មដែលមានប្រាក់បៀវត្សរ៍ទាប និងគុណភាពមានកេរ្តិ៍សមរម្យ។ សមាគមន៍អ្នកកាត់ដេរសំលៀកបំពាក់កម្ពុជា បានសកម្មក្នុងវិស័យនេះ ដែលបំរើជាអ្នកទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពរវាងវិនិយោគិនបរទេសក្នុងវិស័យនេះ និងស្ថាប័នរដ្ឋាភិបាល។ កិច្ចខិតខំប្រឹងប្រែងបន្តរបស់សមាគមន៍នេះ ដើម្បីដោះស្រាយបញ្ហាអវិជ្ជមានដែលកំពុងជួបប្រទះដោយវិនិយោគិនក្នុងឧស្សាហកម្មនេះ បានកំពុង

ដើរតួនាទីយ៉ាងសំខាន់ក្នុងការដណ្ដើមបាននូវទំនុកចិត្តកាន់តែខ្លាំងឡើងរបស់វិនិយោគិនបរទេស និងការអភិវឌ្ឍន៍ក្នុងឧស្សាហកម្មនេះ។ ប៉ុន្តែ នៅមានវិស័យជាច្រើនទៀតដែលកំពុងអំពាវនាវឱ្យមានវិធានការជាបន្ទាន់សំរាប់ការអភិវឌ្ឍន៍ដើម្បីនឹងធ្វើចីរកម្មល្បឿននៃការអភិវឌ្ឍន៍ក្នុងវិស័យទាំងនេះ ដូចខាងក្រោមៈ

- ក្នុងពេលដែលវិស័យនេះ កំពុងតែពឹងផ្អែកលើពលកម្មកម្ពុជាដ៏ច្រើនលើសលុប វាជាការសំខាន់បំផុតដើម្បីពង្រឹងគុណភាពនៃពលកម្មក្នុងទិសដៅបង្កើតផលិតភាព។
- ក្នុងពេលដែលការនាំចេញផលិតផលកាត់ដេរត្រូវបានផ្ដោតលើទីផ្សារសហរដ្ឋអាមេរិក និងអឺរ៉ុប វិធានការប្រកបដោយការជំរុញ និងប្រសិទ្ធភាព គួរតែត្រូវបានលើកយកមកអនុវត្តដើម្បីសំរេចបាននូវពិពិធកម្មទីផ្សារដោយពង្រីកការនាំចេញទៅកាន់ទីផ្សារជប៉ុន រុស្ស៊ី មជ្ឈឹមបូព៌ា និងប្រទេសអាស៊ីដទៃទៀត។
- ឧស្សាហកម្មកាត់ដេរស្ទើរតែទាំងអស់នៅកម្ពុជា កំពុងតែប្រើប្រាស់មូលដ្ឋាន CMP ដូច្នេះវិធានការប្រកបដោយការជំរុញ គួរតែត្រូវបានទទួលយកដើម្បីបានអភិវឌ្ឍន៍ប្រព័ន្ធផលិតនិងនាំចេញ (develop-and-export)។
- វិធានការបន្ថែម គួរតែលើកមកអនុវត្តដើម្បីកាត់បន្ថយពេលវេលាជាមួយនឹងទស្សនៈដើម្បីពង្រឹងភាពប្រជែងឈ្នះ ប្រៀបធៀបទៅនឹងប្រទេសជិតខាង។ មធ្យោបាយមួយដើម្បីកាត់បន្ថយការប្រើប្រាស់ពេលវេលានេះ គឺត្រូវបង្កើតហេដ្ឋារចនាសម្ព័ន្ធឃ្លាំងទំនិញរួចពន្ធគយកណ្ដាល (central-bonded warehouse) នៅតំបន់សេដ្ឋកិច្ចពិសេស ដូច្នេះទើបអ្នកផលិតអាចទិញវត្ថុធាតុដើម ពីឃ្លាំងទំនិញនៅក្នុងតម្លៃសមរម្យ ដែលនាំទៅរកការកាត់បន្ថយការប្រើប្រាស់ពេលវេលា ដែលរួមវិភាគទានជាវិជ្ជមានដល់ការពង្រឹងភាពប្រជែងឈ្នះ នឹងជៀសវាងបាននូវលទ្ធភាពពន្យាក្នុងការដឹកជញ្ជូនទំនិញ ប្រតិវេទន៍កំពង់ផែ។ល។
- ឧស្សាហកម្មកាត់ដេរកម្ពុជា ខ្វះខាតយ៉ាងខ្លាំងនូវឧស្សាហកម្មគាំទ្រ។ ការគូសបញ្ជាក់នៅទីនេះ គួរតែត្រូវបានដាក់ជាការទាក់ទាញការវិនិយោគទាំងក្នុងស្រុក និងបរទេសសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មគាំទ្រ។ ការនេះ នឹងកាត់បន្ថយពេលវេលាដែលជាលទ្ធផលក្នុងកំរិតខ្ពស់នៃភាពប្រជែងឈ្នះ។
- រចនាសម្ព័ន្ធសំខាន់នៃផ្នែកនេះ អាចត្រូវបានពិពណ៌នាដូចខាងក្រោម :

**របាយការណ៍បញ្ចប់**




(២) **ឧស្សាហកម្មកែច្នៃម្ហូបអាហារ ជលផល និងកសិផល** : ឧស្សាហកម្មដទៃទៀត មានសក្តានុពលជាច្រើនក្នុងការលូតលាស់ រួមមានឧស្សាហកម្មកែច្នៃម្ហូបអាហារ ជលផល និងកសិផល។ ឧស្សាហកម្មទាំងនេះ ដើរតួនាទីជាស្នូលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ក្នុងពេលដែលអត្រានៃវិស័យកសិកម្ម និងនេសាទ នៅក្នុងគណនេយ្យ សផផ មានដល់ទៅ ៣២.៩% នៅឆ្នាំ ២០០៤[1]។ ប៉ុន្តែការនាំចេញនៃផលិតផលពាក់ព័ន្ធនឹងកសិកម្ម មានទំហំតិចតួចបំផុត។ ជាការពិត ការនាំចេញកសិផលរបស់កម្ពុជា មានប្រមាណជា ០.០០៩១% នៅក្នុងការនាំចេញកសិផល ក្នុងពិភពលោក នៅឆ្នាំ ២០០៤[2]។ ជាបន្ថែមការកែច្នៃជលផលសមុទ្រ និងម្ហូបអាហារ គឺមានព្រំដែនកំណត់នៅកម្ពុជា។ ការផ្គត់ផ្គង់ និងថ្លៃនៃជលផលសមុទ្រ និងកសិផលសំរាប់កែច្នៃគឺមិនមានស្ថេរភាព។ ការនាំចេញគ្មានច្បាប់នៃកសិផល និងជលផលគឺនៅមាននៅឡើយ។ បញ្ហាទាំងនេះ ធ្វើឱ្យមានការលំបាកក្នុងការជញ្ជូនជលផលសមុទ្រ និងកសិផលដែលឆ្លើយតបទៅនឹងការតំរូវរបស់ឧស្សាហកម្មកែច្នៃម្ហូបអាហារ។ អនុលោមតាមបញ្ហាខ្វះទំនាក់ទំនងរវាងអ្នកផលិត និងក្រុមហ៊ុនកែច្នៃនៅក្នុងឧស្សាហកម្មជលផល និងកសិផលនេះ បានធ្វើឱ្យមានការស្ទាក់ស្ទើររបស់ក្រុមហ៊ុនវិនិយោគបរទេសក្នុងការវិនិយោគនៅកម្ពុជាលើវិស័យទាំងនេះ។ ពីទស្សនៈខាងលើ វាមានសារៈសំខាន់ណាស់សំរាប់រដ្ឋាភិបាលកម្ពុជា ដើម្បីចាត់វិធានជាបន្ទាន់ដូចខាងក្រោម :

- ឧស្សាហកម្មកែច្នៃម្ហូបអាហារនៅកម្ពុជា គួរតែបំរើទាំងឧស្សាហកម្មបំរើការនាំចេញ និងឧស្សាហកម្មជំនួសឱ្យការនាំចូល។
- ទីផ្សារសំរាប់នាំចេញ គឺត្រូវបានពង្រីកទៅកាន់ទីផ្សារសកលលោកជាមួយនឹងភាពប្រជែងឈ្នះនៃថ្លៃ និងគុណភាព ដែលនឹងកសាងនូវកេរ្តិ៍ឈ្មោះរបស់កម្ពុជាក្នុងរយៈពេលវែង។

[1] Source: ADB, Key Indicators 2006
[2] EIC, “Cambodia Agriculture Development Report”, June 2006

- ផលិតផលសំខាន់ៗដែលបច្ចុប្បន្នមានភាពប្រជែងឈ្នះខ្ពស់ និងដែលគួរតែត្រូវបានផ្តោតសំរាប់ពង្រីកផលិតកម្មនោះគឺ ដំឡូងឈើ (ម្សៅដំឡូងមី) ដូងប្រេង ម្ហូបបង្កក (ផលិតផលជលផលកែច្នៃ) ផ្លែឈើត្រូពិក កៅស៊ូ ផលិតផលកសិកម្មសេរីរាង្គ និងផលិតផលកសិកម្មផ្សេងទៀត។
- សហករណ៍នេសាទ និងកសិកម្ម គួរតែត្រូវបានពង្រឹង។ ឧស្សាហកម្មកែច្នៃផលិតផលជលផល និងកសិផល ត្រូវការធ្វើលទ្ធកម្មវត្ថុធាតុដើមពីកសិករ ឬអ្នកនេសាទ ឬក៏បុគ្គលសំខាន់ ឬអ្នកសហការជិតស្និទដែលដើរតួដូចគ្នាទៅនឹងប្រមុខសហព័ន្ធ។
- កម្មវិធីបណ្តុះបណ្តាល និងអប់រំដល់កសិករ និងអ្នកនេសាទ គួរតែត្រូវបានផ្តល់ជូនឱ្យចំតាមការតំរូវចំពោះកំណែលំអផលិតភាព និងគុណភាព។
- ភ្នាក់ងារអធិការកិច្ច និងវាយតម្លៃម្ហូបអាហារ គួរតែត្រូវបានបង្កើតឡើងនៅកម្ពុជា ដើម្បីអាចពង្រីកទីផ្សារនាំចេញ ទៅកាន់ប្រទេសជឿនលឿនរួមទាំងប្រទេសជប៉ុន ដែលប្រទេសទាំងនោះ យកចិត្តទុកដាក់ខ្ពស់ចំពោះអនាម័យម្ហូបអាហារ។
- វាក៏ជាប្រការចាំបាច់ណាស់ដែរដើម្បីបង្កើតឡើងនូវហេដ្ឋារចនាសម្ព័ន្ធសមស្រប ដើម្បីពង្រឹងគុណភាពនៃផលិតផលដែលរួមមានហេដ្ឋារចនាសម្ព័ន្ធផ្ទុកសីតុណ្ហភាពទាប កន្លែងក្លាសេ ឬឃ្លាំងក្លាសេ ប្រព័ន្ធដឹកជញ្ជូនក្លាសេ។
- ជាមួយនឹងទស្សនៈដើម្បីពង្រឹងផលិតភាពនៃវិស័យកសិកម្ម វាជាប្រការចាំបាច់ដើម្បីកែលំអរប្រព័ន្ធធារាសាស្ត្រ។

ជាការបន្ថែមចំពោះសេចក្តីត្រូវការសំរាប់ទទួលយកនូវវិធានការដែលអាចទៅរួចដើម្បីដោះស្រាយ ឬកែលំអវិស័យដែលបានរៀបរាប់ខាងលើ វាជាប្រការចាំបាច់ដើម្បីទទួលយកនូវវិធានការប្រកបដោយប្រសិទ្ធភាព ដើម្បីទាក់ទាញការវិនិយោគបរទេសផ្ទាល់ទៅក្នុងឧស្សាហកម្មកែច្នៃម្ហូបអាហារ ជលផល និងកសិផល ជាមួយនឹងទស្សនៈដែលថានឹងសំរេចឱ្យបាននូវកំណែលំអភ្លាមៗ។ វិធានការចាំបាច់គួរតែរាប់បញ្ចូលដូចមានខាងក្រោម :

- ប្បញ្ញត្តិនៃសេវាកម្មទូលំទូលាយ ចំពោះក្រុមហ៊ុនបរទេសក្នុងវិស័យទាំងនេះ ដែលគួរតែរាប់បញ្ចូលទាំងជំនួយក្នុងការជ្រើសរើសទីតាំងសមស្រប ធ្វើការសិក្សាសមិទ្ធិលទ្ធភាព ការជ្រើសរើសកម្មករ ។ល។
- ប្បញ្ញត្តិនៃពត៌មានពាក់ព័ន្ធច្បាស់លាស់ចាំបាច់ចំពោះនិតិវិធីវិនយោគបរទេស ច្បាប់/បទបញ្ញត្តិ លក្ខខណ្ឌទីផ្សារ ការធ្វើលទ្ធកម្ម ។ល។ ការផ្តល់ពតិមានគួរតែត្រូវកែលំអ ហើយពតិមានទាំងនោះ គួរតែអាចទទួលបាននៅក្រៅប្រទេស។

## របាយការណ៍បញ្ចប់

- គោលនយោបាយ និងបទបញ្ញត្តិពាក់ព័ន្ធ ចំពោះការជំរុញការនាំចេញ គួរតែត្រូវបានកែលំអរ ហើយគោលនយោបាយជំរុញការនាំចេញ គួរតែត្រូវធ្វើឱ្យកាន់តែទាក់ទាញ និងសកម្មថែមទៀត។ វិធានការចាំបាច់ដែលត្រូវលើកឡើង គួរតែរាប់បញ្ចូលផងដែរនូវការកសាងសមត្ថភាពសំរាប់អាជ្ញាធរពាក់ព័ន្ធ ដើម្បីអាចធ្វើគោលនយោបាយសំរាប់ពង្រីកការនាំចេញ សិក្សាអំពីនិតិវិធីនាំចេញ ពង្រឹងភាពប្រជែងឈ្នះ និងផ្តល់សិទ្ធដល់ស្ថាប័នដែលធ្វើការងារជំរុញការនាំចេញ។

រចនាសម្ព័ន្ធសំខាន់នៃផ្នែកនេះ អាចត្រូវពិពណ៌នាដូចខាងក្រោម :




(៣) **ឧស្សាហកម្មផលិតស្បែកជើង :** ទោះបីឧស្សាហកម្មផលិតស្បែកជើងរបស់កម្ពុជា មានសក្តានុពល សំរាប់ការពង្រីកនៃការវិនិយោគបរទេសផ្ទាល់ក៏ដោយ កូដ្ឋកម្ម និងបរាជ័យនៃការគ្រប់គ្រងក្នុងប៉ុន្មានឆ្នាំនេះ បានធ្វើឱ្យក្រុមហ៊ុនបរទេសមួយចំនួនដកចេញពីកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ មានសញ្ញានៃការកែលំអដែលទាក់ទិនទៅនឹងបាតុកម្ម និងបរិស្ថានវិនិយោគក្នុងឧស្សាហកម្មកំពុងតែចេញដំណើរទៅរកភាពប្រសើរឡើងខ្លាំងជាងមុន។ បរិយាកាសវិនិយោគនៅចិន និងវៀតណាម កំពុងតែមានភាពអាក្រក់ឡើង ដោយសារបញ្ហា Anti-Dumping និងការកើនឡើងនៃប្រាក់ឈ្នួលកម្មករ ហើយលំហូរនៃការវិនិយោគបរទេសផ្ទាល់ទាក់ទិនទៅនឹងស្បែកជើងចូលមកកម្ពុជា កំពុងចាប់ផ្តើមកើនឡើងយ៉ាងឆាប់រហ័ស។ សកម្មភាពផលិតកម្ម បានស្តែងចេញយ៉ាងច្បាស់នូវការប្រែប្រួលឆ្ពោះទៅរកការកើនឡើងនៃការវិនិយោគលើវិស័យនេះ។

ពុំមានការចាំបាច់ណាមួយ ដែលត្រូវនិយាយថា កម្ពុជា នឹងផ្តល់នូវឧត្តមភាពប្រជែងឈ្នះសំរាប់ផលិតកម្មស្បែកជើងច្រើនជាងប្រទេសចិន និងវៀតណាមទេ គឺគ្រាន់តែធ្វើការពិចារណាទៅកត្តាដូចជា ការពឹងផ្អែកទាំងស្រុងទៅលើការនាំចូលវត្ថុធាតុដើម បញ្ហាភស្តុភា សមត្ថភាពនៅមានកំរិតដើម្បីទទួលយកនូវសេវាកម្មផលិតពីខាងក្រៅ ព្រមទាំងផលិតភាពនៃពលករនៅមានកំរិតទាបផងនោះ។ បច្ចុប្បន្ន ភាពប្រជែងឈ្នះរបស់កម្ពុជា ត្រូវបានកំណត់ព្រំដែនចំពោះផ្នែកផលិតស្បែកជើងធ្វើពីស្បែក ដែលផ្នែកនេះមានសក្តានុពលសំរាប់ការផ្គត់ផ្គង់ដល់ទីផ្សារ អឺរ៉ុប និងជប៉ុន។ សំណួរថាតើ

កម្ពុជា មានលទ្ធភាពឬអត់ ចំពោះមូលដ្ឋានសំរាប់ឧស្សាហកម្មស្បែកជើងទាំងមូល តាមរយៈផលិតកម្មតែមួយផ្នែកនៃស្បែកជើងផលិតពីស្បែក ដែលវាមានឧត្តមភាពប្រជែងឈ្នះ ដោយហេតុនោះ វាក្លាយទៅជាភាពប្រកួតប្រជែងនៅក្នុងផលិតកម្មស្បែកជើងនាថ្ងៃអនាគត។ ការទាក់ទាញមូលធន បរទេស គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មដូចខាងក្រោម គឺជាប្រការចាំបាច់បំផុតដែលត្រូវលើកយកមកអនុវត្តជា ការប្រញាប់។

- រដ្ឋាភិបាលកម្ពុជា គួរតែផ្តល់អាទិភាពខ្ពស់ចំពោះឧស្សាហកម្ម សំរាប់ការទាក់ទាញការវិនិយោគបរទេសផ្ទាល់នៅជាប់ជាមួយនឹងឧស្សាហកម្មកាត់ដេរ។ ជាពិសេស វាគួរតែត្រូវពិនិត្យមើលនូវគំនិតផ្តួចផ្តើមពិពិធកម្ម សំរាប់ជំរុញប្រកបដោយប្រសិទ្ធភាពទាក់ទិនទៅនឹងការលើកទឹកចិត្តវិនិយោគ លក្ខខណ្ឌការងារ ការអភិវឌ្ឍន៍ធនធានមនុស្ស និងធ្វើឱ្យមានរចនាសម្ព័ន្ធឧស្សាហកម្ម។
- ប្រសិទ្ធភាពការងារ គឺត្រូវបានគិតថាមានភាពអន់នៅឡើយ ដោយសារការអប់រំនៅបឋមសិក្សាមិនគ្រប់គ្រាន់ ហើយត្រូវផ្តល់ចំណាត់ថ្នាក់ចំពោះផលិតភាព ត្រឹមតែ ៣០ ក្នុងពេលដែល ចិនមាន ១០០ និងវៀតណាម មាន ៧០។ ដោយសារតែវាពិបាកក្នុងការរកបុគ្គលិកបង្រៀនសំរាប់កម្មវិធីអប់រំ និងបណ្តុះបណ្តាល ហេតុនេះ ជំរើសនៃការបង្កើតកម្មវិធីក្នុងស្ថាប័នសាធារណៈ គួរតែត្រូវបានសិក្សាជាការប្រញាប់។
- សមាគមន៍ឧស្សាហកម្មស្បែកជើង គឺគ្មានសកម្មភាពទេ ដោយសារតែគ្មានប្រធាន។ សមត្ថភាពនៃសមាគមន៍ គឺជាសារៈសំខាន់សំរាប់រដ្ឋាភិបាលដើម្បីពង្រាយវិធានការផ្សេងៗ ហើយឧស្សាហកម្ម ត្រូវធ្វើសំណើជាគោលនយោបាយចំពោះរដ្ឋាភិបាល។ រដ្ឋាភិបាល គួរតែជំរុញយ៉ាងសកម្មនូវការស្ថាបនាឡើងវិញនូវសមាគមន៍នេះ សំរាប់កំណើនដែលមានរបៀបនៃឧស្សាហកម្មនៅកម្ពុជា សូម្បីតែវាមានការពឹងផ្អែកខ្លាំងទៅលើការវិនិយោគបរទេសផ្ទាល់ក៏ដោយ។
- ការធានាដ៏សមស្របចំពោះការប្រើប្រាស់ពេលវេលាដូចបានកត់សំគាល់ខាងលើផ្អែកលើកាលវិភាគផលិតកម្ម នឹងតំរូវឱ្យមានការចាត់ចែងឡើងវិញនូវការដឹកជញ្ជូនទំនិញក្នុងប្រទេសកម្ពុជា ដើម្បីធ្វើពិពិធកម្មបណ្តាញដឹកជញ្ជូនដោយធ្វើឱ្យមានប្រសិទ្ធភាព។ ការធានានេះ អាចធ្វើទៅបានដោយកែកុនស្ថានភាពរថយន្តដឹកទំនិញ និងការដឹកជញ្ជូនតាមផ្លូវដែកភ្ជាប់ពីទីក្រុងភ្នំពេញជាមួយទីក្រុងបាងកក និងទីក្រុងហូជីមិញ។
- ក្រុមហ៊ុនបរទេស បោះទីតាំងនៅកម្ពុជាលើឧស្សាហកម្មកាត់ដេរ និងស្បែកជើង ត្រូវចំណាយពេលយ៉ាងច្រើនដើម្បីរៀបចំឯកសារ និងទទួលបានការអនុម័តសំរាប់នាំចេញ/នាំចូល។ គំរោងគំរូសំរាប់ការធ្វើសមញ្ញកម្មនិតិវិធីនៅកំពុងផែក្រុងព្រះសីហនុ នឹងត្រូវដាក់ឱ្យប្រើប្រាស់នៅក្នុងឆ្នាំនេះ។ គំរោងនេះ ត្រូវតែនាំទៅរកការជោគជ័យដើម្បីនឹងទាក់ទាញការវិនិយោគថ្មី និងធ្វើឱ្យនិតិវិធីមានភាពរលូនសំរាប់ក្រុមហ៊ុនដែលមានស្រាប់នៅកម្ពុជា។

គំរោងនេះ ត្រូវតែត្រូវអនុវត្តដោយស្ថាប័នពាក់ព័ន្ធផ្សេងទៀត ការធ្វើសមញ្ញកម្មនៃការងារពាក់ព័ន្ធ និងកែតំរូវនូវការអនុវត្តន៍ខុសឆ្គងកន្លងមកចំពោះការយកប្រាក់កំរៃក្រៅ។

- ដើម្បីលើកទឹកចិត្តការវិនិយោគបរទេសផ្ទាល់ចំពោះ ឧស្សាហកម្មស្បែកជើង រដ្ឋាភិបាលកម្ពុជា គួរតែរៀបចំប្លង់មេផ្ទាល់ខ្លួនដែលបង្កើតឡើងនូវចក្ខុវិស័យសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្ម គោលនយោបាយដែលត្រូវលើកមកអនុវត្ត ដើម្បីសំរេចបាននូវចក្ខុវិស័យនេះ ព្រមទាំងការកែលំអរបរិវិនិយោគ។
- ឧស្សាហកម្មស្បែកជើង ត្រូវការគ្រប់ផ្នែកទាំងអស់នៃវត្ថុធាតុដើម និងបំណែក។ និយាយឱ្យចំទៅ ការធ្វើឱ្យជឿនលឿននៃឧស្សាហកម្ម តំរូវឱ្យមានសមាសធាតុចូលរួមក្នុងស្រុក ដើម្បីធ្វើឱ្យប្រាកដប្រជានូវភាពប្រជែងឈ្នះនៃចំណាយថ្លៃដើម។ ក្នុងចំណោមវត្ថុធាតុដើម និងបំណែកផ្សេងៗ នឹងមានទិដ្ឋភាពអនាគតសំរាប់ការដាក់ក្រុមហ៊ុនកែច្នៃស្បែកសត្វនៅកម្ពុជា។ ភាពប្រជែងឈ្នះ នៃស្បែកជើងកម្ពុជា អាចត្រូវបានបង្ហាញយ៉ាងប្រពៃរចំពោះការផលិតស្បែកជើងធ្វើពីស្បែក។ ក្នុងរយៈពេលវែង ឧស្សាហកម្មនេះ គួរតែពិនិត្យឡើងវិញនូវការធ្វើភាវូបនីយកម្មរបស់ក្នុងស្រុកនៃធុរកិច្ចច្នៃស្បែកសត្វ។

រចនាសម្ព័ន្ធសំខាន់ នៃផ្នែកនេះ អាចត្រូវពិពណ៌នាដូចខាងក្រោម :




(៤) **ឧស្សាហកម្មផលិតគ្រឿងអគ្គីសនី/អេឡិកត្រូនិក**

ទោះបីឧស្សាហកម្មផលិតគ្រឿងអគ្គីសនី/អេឡិកត្រូនិក មិនទាន់ត្រូវបានអភិវឌ្ឍន៍នៅកម្ពុជាក៏ដោយ ក៏មានសក្តានុពលជា ច្រើនសំរាប់ការអភិវឌ្ឍន៍លឧស្សាហកម្មទាំងនេះ។ ក្រុមហ៊ុនជប៉ុន ក្នុងឧស្សាហកម្មនេះ កំពុងធ្វើប្រតិបត្តិការនៅក្នុង ប្រទេសជិតខាងរបស់កម្ពុជា ដូចជាថៃ និងម៉ាឡេស៊ី បានបង្ហាញពីចំណាប់អារម្មណ៍ក្នុងការពង្រីកផលិត និងប្តូរទីតាំងផលិត កម្មរបស់ខ្លួនមកកម្ពុជា ដើម្បីនឹងទទួលយកនូវផលប្រយោជន៍ពីតម្លៃថោកនៃពលកម្មរបស់កម្ពុជា។ ជាក់ស្តែង ផលិតផល ចំនួន ៥ ប្រភេទ នឹងមានលទ្ធភាពធ្វើការផលិតនៅកម្ពុជាបាន ដូចជា តំណរខ្សែភ្លើងសំរាប់រថយន្ត គ្រឿងបំណែកដែលប្រើ ពលកម្មច្រើនក្នុងការផលិត ដូចជា ដុំភ្លើង និងឧបករណ៍ទប់ភ្លើង ឧបករណ៍ប្រើអគ្គីសនី ដូចជាផលិតផលរបស់ជាងកាត់សក់ ផលិតផលឧបករណ៍តំឡើងសំលេង ដូចជាឧបករណ៍ផ្គត់ផ្គង់ភ្លើង និងឧបករណ៍ទំនាក់ទំនង និងពតិមានដែលមានតម្លៃទាប។

**របាយការណ៍បញ្ចប់**

លក្ខណៈវិនិច្ឆ័យទាំងនេះ ត្រូវនឹងការសំរេចចិត្តដាក់ទីតាំងរោងចក្រក្នុងចំណោមក្រុមហ៊ុនជប៉ុនក្នុងឧស្សាហកម្មនេះ ឆ្លុះ បញ្ចាំងនូវទំហំដ៏ធំនៃការវិនិយោគ និងធ្វើពិពិធកម្មការផ្គត់ផ្គង់ធនធាន និងផលិតផលទៅកាន់ទីផ្សារនាំចេញ និងប្រើពេល តិចក្នុងកិច្ចសន្យានៃការគួសវាស។ លក្ខណៈវិនិច្ឆ័យជាក់ស្តែង មានរាប់បញ្ចូលស្ថេរភាពនៃស្ថានការនយោបាយសង្គម ការលើកទឹកចិត្តសំរាប់ការវិនិយោគបរទេសផ្ទាល់ក្នុងការផលិត តម្លៃពលកម្មទាប និងឧស្សាហ៍ សួនឧស្សាហកម្មដែលមានហេដ្ឋារចនាសម្ព័ន្ធល្អ បណ្តាញភស្តុភារអន្តរជាតិដែលបង្កលទ្ធភាពដល់ការដឹកជញ្ជូនប្រើពេលតិច និងបរិស្ថានសំរាប់ការស្នាក់ នៅរបស់វិនិយោគិនមានផាសុខភាព និងសុវត្ថិភាព។ ការតំរូវជាសារវន្ត គឺវត្តមានរបស់សួនឧស្សាហកម្មដែលប្រដាប់ដោយ ការផ្គត់ផ្គង់ទឹក ភ្លើងមានស្ថេរភាពល្អ ដែលផ្តល់ផងដែរនូវមុខងាររបស់តំបន់កែច្នៃនាំចេញ និងបណ្តាញភស្តុភារអន្តរជាតិ មួយសំរាប់ការដឹកជញ្ជូនតាមផ្លូវទឹក ផ្លូវគោក និងផ្លូវអាកាស។

ក្នុងករណីនៃឧស្សាហកម្ម ផលិតគ្រឿងអគ្គីសនី/អេឡិកត្រូ និក ផែនការសកម្មភាពដើម្បីទាក់ទាញការវិនិយោគបរទេសផ្ទាល់ជាសំខាន់ក្រុមហ៊ុនជប៉ុន ត្រូវតែផ្តោតលើសេចក្តីត្រូវការសំរាប់ការកសាងនៃធាតុទាំងឡាយនៃហេដ្ឋារចនា-សម្ព័ន្ធជាមូលដ្ឋានសំខាន់ៗ។

- តំបន់សេដ្ឋកិច្ចពិសេសនៅក្រុងព្រះសីហនុ ដែលត្រូវបញ្ចប់ក្នុងឆ្នាំ២០០៩ នឹងត្រូវបង្កើតនូវបទដ្ឋានឱ្យច្បាស់លាស់សំរាប់ដំណើរការតំបន់កែច្នៃនាំចេញ និងធាតុដទៃទៀតនៃគំរោងការនៃការគ្រប់គ្រងព្រមទាំងធាតុជាហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មដូចជា ថាមពលអគ្គីសនី ទឹក និងប្រព្រឹត្តិកម្មទឹកកខ្វក់ផងដែរ។ កំរិតរបស់សួនឧស្សាហកម្ម ត្រូវបានកំណត់ក្នុងដំណើរការនេះ គួរតែត្រូវលើកយកមកអនុវត្តដូចជាបទដ្ឋានមួយដើម្បីអាចអនុវត្តបានដូចសួនឧស្សាហកម្មដែលមានស្រាប់ដូច្នោះដែរ។ ទន្ទឹមនឹងនេះ ការស្ថាបនាសួនឧស្សាហកម្មបន្ថែមនាពេលអនាគត គួរតែធ្វើឱ្យមានបទដ្ឋានដែលយកតាមគំរូតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ។ ក្នុងមាគ៌ានេះ កម្ពុជា ត្រូវតែពង្រីកកំរិតនៃហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មរបស់ខ្លួន។
- ក្នុងបរិយាកាសវិនិយោគ ក្រុមហ៊ុនផលិតគ្រឿងអគ្គីសនី/អេឡិកត្រូនិក បានដាក់ការយកចិត្តទុកដាក់ខ្ពស់ចំពោះវត្តមាននៃប្រព័ន្ធភស្តុភារអន្តរជាតិ ដែលអាចឱ្យគេធ្វើការនាំចូលវត្ថុធាតុដើម និងគ្រឿងបន្សំពីប្រទេសផ្សេង និងងាយស្រួលក្នុងការនាំចេញផលិតផល។ ជាមួយនឹងជំនួយរបស់រដ្ឋាភិបាលជប៉ុន និងប្រទេសផ្សេងទៀត ការងារកែលំអរកំពង់ផែ និងបណ្តាញផ្លូវគមនាគមន៍ ត្រូវបានសង្ឃឹមទុកថានឹងធ្វើឱ្យមានវឌ្ឍនៈភាពជាច្រើននៅឆ្នាំ ២០១០។ កម្ពុជា ត្រូវតែធ្វើឱ្យបានរហ័សនូវល្បឿននៃការងារនេះសំរាប់ការបញ្ចប់ឱ្យបានមុនពេលកំណត់។
- ការទាក់ទាញការវិនិយោគបរទេសផ្ទាល់ តំរូវឱ្យមានការជំរុញ (តាមគ្រប់មធ្យោបាយ) នៃផលប្រយោជន៍ដែលផ្តល់ដោយកម្ពុជា និងបរិស្ថានវិនិយោគរបស់វា ដែលកំពុងតែដើរឆ្ពោះទៅរកការកែលំអ។ ជាក់ស្តែង

ជាងនេះ សកម្មភាពដែលបានផ្តល់ជាអនុសាសន៍ រាប់បញ្ចូលទាំងការរៀបចំសិក្ខាសាលាដោយ ក.អ.ក/គ.វ.ក នៅជប៉ុន និងនៅប្រទេសជិតខាង ការបង្កើត "ការិយាល័យជប៉ុន" (រាប់ទាំងការបញ្ជូនជំនាញការ JICA) ក្នុងគោលដៅជួយទាក់ទាញការវិនិយោគពីជប៉ុន អភិក្រមការទូតកម្រិតខ្ពស់ដែលដឹកនាំដោយប្រមុខរដ្ឋាភិបាល ប្រមុខរដ្ឋ និងរដ្ឋមន្ត្រី សំរាប់ការទាក់ទាញការវិនិយោគ និងការរៀបចំសៀវភៅមគ្គុទេសក៍វិនិយោគ។

- ដូចការងារជាបឋមមួយ ការកែលំអការអប់រំ គួរតែត្រូវធ្វើជាជំហាន១ចាប់ពីបឋមសិក្សា រហូតដល់មធ្យមសិក្សាកំរិតខ្ពស់ ដើម្បីនឹងបង្កើតអត្រាអក្ខរកម្ម និងផ្តល់ឱ្យនូវចំណេះដឹងជាមូលដ្ឋានក្នុងវិទ្យាសាស្ត្រ។ ទោះបីផលិតកម្មក្នុងឧស្សាហកម្មផលិតគ្រឿងអគ្គិសនី/អេឡិកត្រូនិក គឺជាឧស្សាហកម្មអតិពលកម្មជាមូលដ្ឋានរោងចក្រត្រូវបំពាក់ដោយហេដ្ឋារចនាសម្ព័ន្ធផលិតកម្មជាច្រើន ហើយផលិតកម្ម និងដំណើរការគឺត្រូវបានត្រួតពិនិត្យ និងគ្រប់គ្រងយ៉ាងតឹងរឹងបំផុត។
- សំរាប់ក្រុមហ៊ុនបរទេស បាននឹងកំពុងពិនិត្យមើលឱកាសវិនិយោគនៅកម្ពុជា សំរាប់ផលិតកម្មប្រកួតប្រជែងតាមរយៈថ្លៃ ដោយប្រើប្រាស់ពលកម្មថ្លៃទាបប៉ុន្តែឧស្សាហ៍ព្យាយាម បញ្ហានៃលក្ខខណ្ឌការងារ ដូចជាម៉ោងធ្វើការងារ និងការបង់ថ្លៃឈប់សំរាកផ្សេងៗ អាចជាកត្តាជំរុញសំរាប់ការវិនិយោគរបស់ពួកគេ។ ក្រុមហ៊ុនទាំងនេះ បានចង្អុលបង្ហាញផងដែរថា ការកែលំអចាំបាច់ត្រូវធ្វើដូចជាបញ្ហាសហជីពកម្មករ ដែលកំពុងតែធ្វើឱ្យផ្ទុះនូវវិវាទដ៏ស្រួចស្រាល់នៅក្នុងឧស្សាហកម្មកាត់ដេរ។ ការទាក់ទាញការវិនិយោគបរទេសផ្ទាល់ ក្នុងឧស្សាហកម្មផលិតគ្រឿងអគ្គិសនី/អេឡិកត្រូនិក រដ្ឋាភិបាលកម្ពុជា គួរតែពិនិត្យលើលក្ខខណ្ឌការងារឱ្យបានដូចប្រទេសជិតខាង ហើយការបង្កើតសហជីពកម្មករ ផ្អែកលើចំណងនៃការទុកចិត្តជាមួយអ្នកគ្រប់គ្រងក្រុមហ៊ុន។

រចនាសម្ព័ន្ធសំខាន់នៃផ្នែកនេះ អាចត្រូវពិពណ៌នាដូចខាងក្រោម :

ស្ថានភាពបច្ចុប្បន្ននៃឧស្សាហកម្មផលិតគ្រឿងអគ្គិសនី/អេឡិកត្រូនិក និងគំរូធុរកិច្ចដែលអាចមាន → និន្នាការនៃការវិនិយោគបរទេសផ្ទាល់ នៅក្នុងអេឡិកត្រូនិក និងទស្សនៈវិស័យសំរាប់កម្ពុជា → អនុសាសន៍ជាយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីអភិវឌ្ឍន៍វិស័យអេឡិកត្រូនិកធម្មតា

## (៥) ឧស្សាហកម្មគ្រឿងម៉ាស៊ីន

ឧស្សាហកម្មផ្សេងទៀតដែលមិនទាន់មានការអភិវឌ្ឍន៍កម្ពុជា ប៉ុន្តែមានទិដ្ឋភាពអនាគត រាប់បញ្ចូលទាំងឧស្សាហកម្ម គ្រឿងម៉ាស៊ីនផងដែរ។ បរិមាណឧស្សាហកម្មគ្រឿងម៉ាស៊ីននៅកម្ពុជា មានប្រមាណជា ៣%នៃបរិមាណសរុបនៃឧស្សាហកម្ម។ ៣៣ ភាគរយ (១២ក្រុមហ៊ុន) នៃឧស្សាហកម្មនេះ ត្រូវបានពាក់ព័ន្ធទៅនឹងការផលិតសន្លឹកដែក ២៥% (៣

ក្រុមហ៊ុន) ក្នុងការផលិតម៉ូតូ និងនៅសល់ប៉ុន្មានទៀតពាក់ព័ន្ធនឹង ការផលិតសំភារៈសាងសង់ បរិក្ខាចម្រ្កានបាយ បាសាំងទឹក ទូរទស្សន៍/កុំព្យូទ័រ និងផ្សារអគ្គិសនី។ លំហូរការវិនិយោគបរទេសផ្ទាល់ចំពោះវិស័យម៉ាស៊ីននេះ គឺមានកំរិតតិច តួចបំផុតនៅកម្ពុជា។ សាខាក្រុមហ៊ុនជប៉ុនចំនួន ២ គឺសាជីវកម្មម៉ូទ័រស៊ុយហ្ស៊ុយគី កំពុងផលិតម៉ូតូ និងឧស្សាហកម្ម សង្កសីបូពា (បានវិនិយោគពីសាជីវកម្មស៊ុមីតូម៉ូមួយចំណែក) កំពុងផលិត និងកែច្នៃសន្លឹកដែកក្រូមេ។ ទោះបីផ្នែកនេះ មានសក្តានុពលយ៉ាងសំបើមសំរាប់លូតលាស់ក៏ដោយ ល្បឿននៃការអភិវឌ្ឍន៍ គឺនៅមានកំរិត ដោយសារតែបញ្ហាមួយចំនួន តំរូវឱ្យមានសំណងប្រកបដោយប្រសិទ្ធភាពដូចខាងក្រោម :

- ឧស្សាហកម្មគាំទ្រក្នុងវិស័យនេះ នៅមានកំរិត ដោយសារតែរោងចក្រតម្លើងនៅមានកំរិត ហើយដែនកំណត់ បានរាំងដល់ល្បឿននៃការអភិវឌ្ឍន៍ នៃឧស្សាហកម្មគ្រឿងម៉ាស៊ីននៅកម្ពុជា។ រដ្ឋាភិបាល គួរតែលើក វិធានការចាំបាច់ដើម្បីទាក់ទាញទាំងអ្នកតម្លើង និងឧស្សាហកម្មគាំទ្រ ដើម្បីអភិវឌ្ឍន៍វិស័យនេះ។
- មធ្យោបានតែមួយគត់ ដើម្បីសំរេចឱ្យបាននូវការអភិវឌ្ឍន៍ចាប់រហ័សក្នុងវិស័យនេះ គឺត្រូវធ្វើការទាក់ទាញ ការវិនិយោគបរទេសផ្ទាល់ក្នុងឧស្សាហកម្មគ្រឿងម៉ាស៊ីន ហើយផ្ទេរបច្ចេកវិទ្យាជឿនលឿនចាំបាច់ចំពោះ វិស័យនេះ។ ដូចនោះ ការវិនិយោគបរទេសផ្ទាល់ និងការផ្ទេរបច្ចេកវិទ្យា គឺជាកំលាំងចលករសំរាប់ការអភិ វឌ្ឍន៍ឧស្សាហកម្មនេះ។ ឧស្សាហកម្មជំនួសការនាំចូលក្នុងវិស័យឧស្សាហកម្ម គួរតែត្រូវអភិវឌ្ឍន៍ជាបឋម និងជាបន្ទាប់គឺការអភិវឌ្ឍន៍ឧស្សាហកម្មតំរង់ទិសឆ្ពោះទៅការនាំចេញ។
- ឧស្សាហកម្មគ្រឿងម៉ាស៊ីនដឹកជញ្ជូន និងផលិតកម្មនៃបំណែកដែលជាឧស្សាហកម្មអតិពលកម្ម គួរតែត្រូវបាន អភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា។ ក្នុងរយៈពេលខ្លី កម្ពុជា គួរតែត្រូវការប្រើប្រាស់គ្រឿងបំណែកចាំបាច់ផ្សេងៗ ពីប្រទេសជិតខាងក្នុងតំបន់។ ផលិតកម្មក្នុងស្រុកនៃគ្រឿងបំណែក និងសំភារៈ គួរតែត្រូវបានអភិវឌ្ឍន៍នៅ ក្នុងរយៈពេលមធ្យម និងក្រុមហ៊ុនកម្ពុជាខ្លះ នឹងបានប្រមូលបច្ចេកវិទ្យា ហើយចាប់ផ្តើមផលិតប្រភេទផលិត ផលទាំងនេះក្នុងតំលៃខ្ពស់។ កំរងឧស្សាហកម្មក្នុងប្រទេសកម្ពុជា គួរតែត្រូវបានអភិវឌ្ឍន៍ពេញលេញក្នុង រយៈពេលវែង ដែលនឹងផ្តល់ជាលទ្ធផលនូវផលិកម្មដែលធ្វើការផលិតនូវផលិតច្រើនមុខ ចាប់ពីគ្រឿងបរិក្ខា បន្ទំ រហូតដល់គ្រឿងបំណែកដែលមានតម្លៃបន្ថែម។
- តម្លៃថាមពលខ្ពស់ លំហូរចូលនូវទំនិញគេចពន្ធគយក្នុងតម្លៃទាប ការកំហិតកំណត់លើសំភារៈ និងម៉ាស៊ីន សំរាប់ការផលិត និតិវិធីសំរាប់ការនាំចេញ-ចូល ព្រមទាំងថ្លៃដើមផលិតកម្មខ្ពស់ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធ មិនល្អ បានដាក់កំរិតលើការទាក់ទាញការវិនិយោគផ្ទាល់។ វាជាការសំខាន់ដើម្បីលើកយកនូវវិធានការចាំ បាច់ ដើម្បីលុបបំបាត់នូវការរាំងស្ទះទាំងអស់នេះ។ កំណែលំអនៃហេដ្ឋារចនាសម្ព័ន្ធឱ្យបានសមស្រប និងការ អភិវឌ្ឍន៍នៃស្នូនឧស្សាហកម្ម គឺជាកំលាំងចលករសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្មគ្រឿងម៉ាស៊ីន។ ដូចបាន

រំពឹងទុកជាមុន ចំនួននៃសួនឧស្សាហកម្មដែលបានអភិវឌ្ឍន៍សំរាប់ពាណិជ្ជកម្មជាមួយក្រុមហ៊ុនបរទេស នឹងកើនឡើងតាមរយៈការអនុម័តអនុក្រឹត្យស្តីតំបន់សេដ្ឋកិច្ចពិសេស។ ការបង្កើតច្បាប់ និងបទប្បញ្ញត្តិនានាក្រោមគំនិតផ្តួចផ្តើមនៃរដ្ឋាភិបាល នឹងពន្លឿនការអភិវឌ្ឍន៍នៃសួនឧស្សាហកម្មទាំងនេះ។

- វិធានការចាំបាច់នានា គួរតែត្រូវបានលើកយកមកធ្វើដើម្បីធ្វើការគូសបញ្ជាក់នូវការអភិវឌ្ឍន៍នូវឧស្សាហកម្មគាំទ្រ។ វិធានការបែបនោះ គួរតែរាប់បញ្ចូលនូវការរៀបចំនៃក្របខ័ណ្ឌស្ថាប័នសំរាប់ការអភិវឌ្ឍន៍នៃឧស្សាហកម្មគាំទ្រ ការពង្រីកនៃសកម្មភាពជំរុញការវិនិយោគ ការកែលំអនៃកំរិតជំនាញ និងបច្ចេកវិទ្យានៃឧស្សាហកម្មគាំទ្រ ការអភិវឌ្ឍន៍ធនធានមនុស្ស នៃឧស្សាហកម្មគាំទ្រ និងអប់រំនូវជំនាញគ្រប់គ្រងទៅដល់អ្នកទទួលកិច្ចសន្យាបន្ត។

រចនាសម្ព័ន្ធសំខាន់នៃផ្នែកនេះ អាចត្រូវពិពណ៌នាដូចខាងក្រោម :




## ២.២ បញ្ហាស្ថាប័ន

បញ្ហាស្ថាប័នផ្តោតជាសំខាន់លើការកែលំអនៃក្របខ័ណ្ឌច្បាប់ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មដែល រាប់បញ្ចូលនូវការអភិវឌ្ឍន៍នៃហេដ្ឋារចនាសម្ព័ន្ធអគ្គីសនី ទូរគមនាគមន៏ ផ្លូវថ្នល់ អាកាសចរណ៏ អាយស្ម័យយានកំពង់ផែ សមុទ្រ ការដឹកជញ្ជូនតាមផ្លូវទឹកសាប និងធនធានទឹក។ ផ្នែកនេះ ផ្តោតលើកាអភិវឌ្ឍន៍នៃច្បាប់ទាំងនេះហេដ្ឋារចនាសម្ព័ន្ធ ឧស្សាហកម្ម ជាមួយនឹងទស្សនះដើម្បីជំរុញការវិនិយោគជាសំខាន់គឺការវិនិយោគបរទេសផ្ទាល់។

រចនាសម្ព័ន្ធសំខាន់នៃផ្នែកនេះ អាចត្រូវពិពណ៌នាដូចខាងក្រោម :




## ២.២.១ វិធានការសំរាប់កែលំអក្របខ័ណ្ឌច្បាប់

ទោះបីកម្ពុជា កំពុងក្លាយទៅជាប្រទេសដែលវិនិយោគិនបរទេសមានការចាប់អារម្មណ៍សំរាប់ការវិនិយោគ និង ការប្តូរទីតាំងផលិតកម្មពីប្រទេសជិតខាងក៏ដោយ ក៏កម្ពុជា នៅមានភាពខ្សោយជាច្រើនក្នុងក្របខ័ណ្ឌច្បាប់របស់ខ្លួន។ ទោះបីរដ្ឋាភិបាលកម្ពុជា បាននឹងកំពុងខិតខំប្រឹងប្រែងកែលំអក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ ច្បាប់សំខាន់ៗ រាប់បញ្ចូល ក្រមរដ្ឋប្បវេនី ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ច្បាប់ស្តីពីការធានាចម្លងការ ច្បាប់ស្តីពីក្ស័យធន ច្បាប់ស្តីពីការប្រឆាំងនឹងការលក់ទំនិញថោកជាងថ្លៃដើមក្នុងស្រុក វិធានការសុវត្ថិភាព និងទូទាត់ពន្ធគយ ច្បាប់ស្តីពីបទដ្ឋានឧស្សាហកម្ម ក្រមគយ ច្បាប់ស្តីពីរដ្ឋបាលស៊ីវិល នៅពុំទាន់បានអនុម័តនៅឡើយ។ ជាបន្ថែមលើនេះ វាជាប្រការចាំបាច់ណាស់ដើម្បីកែលំអ ឬធ្វើវិសោធនកម្មនៃច្បាប់មានស្រាប់ខ្លះ ជាឧទាហរណ៍ ច្បាប់ស្តីពីការងារ ច្បាប់ស្តីពីវិនិយោគ ។ល។

អនុក្រឹត្យស្តីពីតំបន់សេដ្ឋកិច្ចពិសេស តំរូវផងដែរនូវការគូសបញ្ជាក់ឱ្យច្បាស់ និងការអនុម័តច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស កំពុងត្រូវបានរង់ចាំដើម្បីផ្តល់នូវមូលដ្ឋានច្បាប់ច្បាស់លាស់សំរាប់គំរោងការនៃតំបន់សេដ្ឋកិច្ចពិសេស។ ក្នុងឱកាសនៃការ អនុម័តច្បាប់ វាអាចផ្តល់ជាអនុសាសន៍ដើម្បីផ្តល់ជូនវិនិយោគិនតំបន់នូវការលើកទឹកចិត្តដែលមិនមែនជាសារពើពន្ធឱ្យបាន ច្រើនជាងនេះ។

## ២.២.២ វិធានការសំរាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម

ការអភិវឌ្ឍន៍សមស្រប នៃហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម ដើរតួនាទីយ៉ាងសំខាន់ក្នុងទស្សនៈដើម្បីជំរុញការវិនិយោគ បរទេសផ្ទាល់ និងការអភិវឌ្ឍន៍ឧស្សាហកម្ម។ ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ តំរូវឱ្យមានការអភិវឌ្ឍន៍ឧស្សាហកម្ម

និងការជំរុញការវិនិយោគបរទេសផ្ទាល់ រាប់បញ្ចូលទាំងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់សេដ្ឋកិច្ចពិសេស អគ្គិសនី ទូរគមនាគមន៍ ផ្លូវថ្នល់ អាកាសចរណ៍ ផ្លូវដែក កំពង់ផែសមុទ្រ និងធនធានទឹក។

ទាក់ទិនទៅនឹងការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស ទោះបីការលើកទឹកចិត្តមួយចំនួនដែលផ្តល់ដោយអនុក្រឹត្យតំបន់សេដ្ឋកិច្ចពិសេស ចំពោះអ្នកអភិវឌ្ឍន៍តំបន់ និងវិនិយោគិនតំបន់ក៏ដោយ ក៏ការលើកទឹកចិត្តមិនមែនសារពើពន្ធដែលមានការទាក់ទាញច្រើន គួរតែត្រូវបានផ្តល់ជាបន្ថែម។ ការផ្តល់ការលើកទឹកចិត្តទាំងនេះ គួរតែរាប់បញ្ចូលការកែលំអតម្លាភាពលើការយកប្រាក់កំរៃ និងថ្លៃសេវា ប្បញ្ញត្តិនៃកម្មករដែលមានគុណវុឌ្ឍដោយរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស មិនគិតឈ្នួល ឬក៏យកក្នុងតម្លៃមានតែនាម ណែនាំកិច្ចសន្យាការងាររួមគ្នា កាត់បន្ថយថ្លៃសំរាប់ការបណ្តុះបណ្តាវិជ្ជាជីវៈ ដោយនិយោជកពីការរកបាននូវចំណូលសុទ្ធនៃគំរោងវិនិយោគ លើកលែងពន្ធលើប្រាក់បុរេចំណេញពីវិនិយោគិន និងអនុញ្ញតឱ្យមានការ ទូទាត់ប្រាក់ពន្ធប្រចាំឆមាស ។ល។ លើសពីនេះទៀត លក្ខខណ្ឌអនុគ្រោះច្រើនទៀតសំរាប់វិនិយោគិនតំបន់ គួរតែត្រូវបានផ្តល់។ ទាំងអស់នេះ គួរតែអនុញ្ញត្តិឱ្យវិនិយោគិននាំចូលធាតុចូលផលិតកម្មដោយគ្រាន់តែផ្តល់ជូននូវការប្រកាសការនាំចូល អនុវត្តប្រព័ន្ធ "បញ្ជរតែមួយ" សំរាប់ត្រួតពិនិត្យការនាំចេញ-ចូល អនុវត្តការគ្រប់គ្រងហានិភ័យ ឬសវនកម្មប្រតិវេទ៍តាមក្រោយចំពោះគ្រប់ការនាំចូល លើកលែងការធ្វើអធិការកិច្ចនៅរោងចក្រមុនពេលវេចខ្ចប់ ដាក់កំហិតចំពោះការធ្វើបាតុកម្មពីសំណាក់កម្មករនៅក្នុងតំបន់។ ការលើកទឹកចិត្តមិនមែនសារពើពន្ធជាបន្ថែម ត្រូវបានផ្តល់ចំពោះវិនិយោគិននៅក្នុងតំបន់ឧស្សាហកម្មទូទៅ គួរតែរាប់បញ្ចូលការធានាចំពោះប្បញ្ញត្តិនៃ "ច្រកចេញ-ចូល តែមួយ" ផ្តល់នូវ "កំចីពីរជំហាន" ចំពោះសហគ្រាសធុនតូច-មធ្យមក្នុងស្រុកនៅក្នុងតំបន់ឧស្សាហកម្មទូទៅ កាត់បន្ថយការតំរូវនូវទុនវិនិយោគអប្បបរិមា ដើម្បីនឹងជំរុញ សហគ្រាសធុនតូច-មធ្យម បង្កើតមជ្ឈមណ្ឌលភ្ញាស់ឧស្សាហកម្ម នៅក្នុងតំបន់ឧស្សាហកម្មទូទៅ ដើម្បីផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបង្កើតមជ្ឈមណ្ឌលផ្នែកទីផ្សារ ដើម្បីនឹងជួយក្នុងសកម្មភាពផ្សព្វផ្សាយទីផ្សារនៃសហគ្រាសធុនតូច-មធ្យមនៅក្នុងតំបន់ឧស្សាហកម្មទូទៅ ជួយសហគ្រាសធុនតូច-មធ្យម ដើម្បីអភិវឌ្ឍន៍វេបសៃត៍ និងរៀបចំការតាំងពិពណ៌ផលិតផល និងពាណិជ្ជកម្មសំរាប់ពួកគេ ។ល។

ទាក់ទិនទៅនឹងហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ទោះបីជាការផ្គត់ផ្គង់អគ្គិសនីដោយ អគ្គិសនីកម្ពុជា ក៏ដោយ ក៏មានបញ្ហារាំងស្ទះ មួយចំនួនកើតមានចំពោះវិនិយោគិនដែលបានវិនិយោគហើយ ក៏ដូចជាវិនិយោគិនអនាគតផងដែរ។ បញ្ហាទាំងនេះ រាប់បញ្ចូលទាំងតម្លៃអគ្គិនីខ្ពស់សំរាប់អគ្គិសនីដែលផ្គត់ផ្គង់ដោយ អគ្គិសនីកម្ពុជា និងអ្នកផ្គត់ផ្គង់ឯករាជ្យព្រមទាំងកង្វះខាត នូវហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីតភ្ជាប់ពីតំបន់ជាយុទ្ធសាស្រ្តសំខាន់ៗរបស់កម្ពុជា។ ទោះបីវាត្រូវបានរំពឹងថាបញ្ហាស្ទើរតែទាំង អស់នោះ នឹងត្រូវបានដោះស្រាយនៅឆ្នាំ ២០១០ (យោលទៅតាមផែនការអភិវឌ្ឍន៍របស់រដ្ឋាភិបាល) ក៏ដោយ ក៏វិធានការ ប្រកបដោយប្រសិទ្ធភាព គួរតែត្រូវលើកយកមកធ្វើដើម្បីពន្លឿនការអភិវឌ្ឍន៍ទាំងនោះ។

ទាក់ទិនទៅនឹងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ ទោះបីជាមានការកែលំអសំខាន់ជាភស្តុតាងក្តី ក៏មានកង្វះខាតជាបន្តទៀតចំពោះសេវាកម្មទូរស័ព្ទខ្សែរដែរ។ បើប្រៀបធៀបជាមួយប្រទេសជាសមាជិកអាស៊ានដទៃទៀត ដង់ស៊ីតេនៃការប្រើប្រាស់ទូរស័ព្ទរបស់កម្ពុជា នៅទាបនៅឡើយ ហើយតម្លៃនៃការហៅជាអន្តរជាតិនៅតែខ្ពស់។ ជាមួយទស្សនះដើម្បីកែលំអសេវាកម្មទូរគមនាគមន៍ វាជាការសំខាន់ណាសដើម្បីកាត់បន្ថយតម្លៃហៅតាម ទូរស័ព្ទជាអន្តរជាតិទាំងហៅចេញ និងហៅចូល ទាំងទូរស័ព្ទខ្សែ និងទូរស័ព្ទដៃ និងតម្លៃអ៊ីនធើណេត បង្កើនសមត្ថភាព ទូរស័ព្ទដៃ ដើម្បីបំរើបានតាមតំរូវការនៅម៉ោងរវល់ខ្លាំងនៅតំបន់ទីក្រុង ពង្រីកបណ្តាញឆ្អឹងខ្នងជាតិនៃអ៊ិនធើណេតទៅគ្រប់ ខេត្ត កែលំអការភ្ជាប់អ៊ិនធើណេតជាអន្តរជាតិ ដើម្បីធ្វើឱ្យការតភ្ជាប់អ៊ិនធើណេតក្នុងល្បឿនលឿនជាមួយប្រទេសដទៃទៀត និងពង្រីកការភ្ជាប់ទៅរលកអាកាសធំនៃសេវាអ៊ិនធើណេត និងតភ្ជាប់ទៅនឹងខ្សែអុបទិក។

ទាក់ទិនទៅនឹងហេដ្ឋារចនាសម្ព័ន្ធ បណ្តាញផ្លូវថ្នល់នៅកម្ពុជា បានចាប់ផ្តើមអភិវឌ្ឍន៍នៅដើមទសវត្ស ១៩០០ និងគ្របដណ្តប់សរុបប្រមាណជា ៣៩,៣១០ គ.ម ដែលមាន ៤,៦៩៥ គ.ប ជាផ្លូវជាតិ ៦,៦១៥ គ.ម ជាផ្លូវនៅក្នុងខេត្ត និង ២៨,០០០ គ.ម ជាផ្លូវលំនៅតាមជនបទ។ នៅកម្ពុជា គ្មានផ្លូវរថល្បឿនដាច់ពីគេទេ។ ដង់ស៊ីតេផ្លូវថ្នល់ (គ.ម/គ.ម$^{២}$) គឺអាចប្រៀបធៀបជាមួយប្រទេសអាស៊ានផ្សេងទៀតបាន ប៉ុន្តែសំរាប់ផ្លូវលំនៅមានកំរិតទាបជាងនៅឡើយ។ ដោយសារទឹកជំនន់ដ៏ធំកាលពីឆ្នាំ២០០០ បានធ្វើឱ្យកម្ពុជា មានការខូចខាតយ៉ាងខ្លាំងនូវបណ្តាញផ្លូវមួយចំនួន។ ការស្តារឡើងវិញនូវបណ្តាញផ្លូវកំពុងតែធ្វើយ៉ាងសស្រាក់សស្រាំតាមរយៈជំនួយជាអន្តរជាតិ។ កម្មវិធីស្តារឡើងវិញប្រមាណជា ៩៨% ត្រូវបានរំពឹងថានឹងត្រូវបញ្ចប់ឱ្យបាននៅឆ្នាំ២០០៨ខាងមុខសំរាប់ការកែលំអរផ្លូវជាតិលេខ១ ដល់លេខ៧ ហើយកំណត់ផ្លូវជាតិលេខ ១ នឹងត្រូវបញ្ចប់នៅឆ្នាំ២០១០។ ដោយការដឹកជញ្ជូនតាមផ្លូវគោក ដើរតួនាទីសំខាន់នៅកម្ពុជា វិធានការនានា គួរតែត្រូវបានលើកមកធ្វើដើម្បីពន្លឿនកម្មវិធីស្តារនីតិសម្បទា និងជួសជុលឡើងវិញនូវផ្លូវថ្នល់ទាំងអស់នោះឱ្យបានឆាប់ ព្រោះវាមិនមែនសំរាប់តែអ្នកដំណើរប៉ុណ្ណោះទេ ប៉ុន្តែសំរាប់ការដឹកជញ្ជូនទំនិញក៏ត្រូវការដែរ។

ទាក់ទិនទៅនឹងហេដ្ឋារចនាសម្ព័ន្ធអាកាសចរណ៍ បច្ចុប្បន្នមានជើងហោះហើរជាអន្តរជាតិប្រមាណជា ៧ ជើងទៅកាន់ប្រទេសផ្សេងៗ/តំបន់ ដោយហោះចេញពីព្រលានយន្តហោះអន្តរជាតិភ្នំពេញ ហើយជើងហោះហើរខ្លះត្រូវឆ្លងកាត់សៀមរាប។ មានព្រលានយន្តហោះអន្តរជាតិពីរនៅកម្ពុជា គឺព្រលានយន្តហោះអន្តរជាតិភ្នំពេញ និងព្រលានយន្តហោះអន្តរជាតិសៀមរាប។ ព្រលានយន្តហោះកងកេងនៅទីក្រុងព្រះសីហនុ បានបើកឱ្យប្រតិបត្តិការ សំរាប់ជើងហោះហើរក្នុងស្រុកកាលពីថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០៧ និងកំពុងមានផែនការចាប់ផ្តើមសេវាកម្មហោះហើរជាអន្តរជាតិ ក្នុងពេលអនាគត។ ហើយព្រលានយន្តហោះកំពង់ឆ្នាំង ដែលស្ថិតនៅភាគខាងជើងនៃទីក្រុងភ្នំពេញ បានកំពុងមានផែនការ ដើម្បីចាប់ផ្តើមបន្តប្រតិបត្តិការនាពេលអនាគតដែរ។ ព្រលានយន្តហោះអន្តរជាតិ ភ្នំពេញ សៀមរាប និងកងកេង ត្រូវបានផ្តល់កិច្ចសន្យាបន្តទៅឱ្យក្រុមហ៊ុនរួមគ្នារវាង ម៉ាឡេស៊ី និងបារាំងសំរាប់ធ្វើប្រតិបត្តិការ គ្រប់គ្រង និងអភិវឌ្ឍន៍។

**របាយការណ៍បញ្ចប់**

ពាក់ព័ន្ធនឹងផ្លូវដែក កម្ពុជា មានផ្លូវដែកពីរខ្សែ។ ល្បឿនរត់នៃរថភ្លើងនៅលើផ្លូវដែកនេះជាមធ្យម គឺនៅតិចជាង ៣០ គ.ម/មួយម៉ោង ហើយផ្លូវដែកនេះ មានសភាពទ្រុឌទ្រោមខ្លាំង កន្លែងខ្លះគ្មានឈើ ឬគន្លឹះសំរាប់ទ្រដែកទៀត ព្រមទាំងគ្មានផ្លាកសញ្ញាចរាចរណ៍នៅតាមផ្លូវដែកទាំងពីរខ្សែនេះផងដែរ។ ចាប់តាំងពីធនាគារអភិវឌ្ឍន៍អាស៊ី បាននឹងកំពុងអនុវត្តគំរោងមួយហៅថា "ការសិក្សាសំរាប់ស្តារឡើងវិញនូវផ្លូវដែកនៅកម្ពុជា" នឹងកំពុងផ្តោតគោលដៅលើការធ្វើឱ្យប្រសើរឡើងនូវស្ថានការផ្លូវដែកក្នុងទឹកប្រាក់ប្រមាណជា ២០លានដុល្លាក្នុងរយៈពេល ៣ឆ្នាំ។ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវដែក ត្រូវបានរំពឹងថានឹងមានកំណែលំអ ហើយល្បឿនជាមធ្យម ត្រូវបានរំពឹងថានឹងកើនដល់ទៅ ៥០ គ.ម/ម៉ោង។ ប្រសិនបើធ្វើបានដូច្នោះ វិធានការទាំងឡាយ គួរតែលើកមកអនុវត្តដើម្បីណែនាំនូវប្រព័ន្ធសញ្ញាចរាចរណ៍សំរាប់មូលហេតុសុវត្ថិភាព។

ទាក់ទិនទៅនឹងកំពង់ផែសមុទ្រ កម្ពុជា មានកំពង់ផែសមុទ្រទឹកជ្រៅមួយកន្លែងនៅទីក្រុងព្រះសីហនុ។ ជំហានទី ១ នៃការពង្រីកកន្លែងដាក់កុងទែនើរ គឺមានប្រវែង ២៤០ ម៉ែត្រ បានសាងសង់រួចរាល់ជាស្ថាបពរ និងជំហានទី ២ នៃការពង្រីកប្រមាណជា ១៦០ ម៉ែត្រទៀត ត្រូវបានរំពឹងថានឹងត្រូវបានកំពុងតែអនុវត្ត។ កំពង់ផែនេះ ត្រូវបានរំពឹងថានឹងជាកំពង់ផែអន្តរជាតិ និងជាទីផ្នែកនៃវិនិយោគិនក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុផងនោះ។ ក្នុងពេលនោះ កំពង់ផែតូចៗ ដែលធ្វើប្រតិបត្តិការនៅជិតកំពង់ផែក្រុងព្រះសីហនុ នឹងរំពឹងថាអាចបានទទួលបរិមាណច្រើននៃកុងទែនើរតូចៗ ដែលដឹកជញ្ជូនតាមកប៉ាល់តូចៗ។

ទាក់ទិននឹងការដឹកជញ្ជូនតាមផ្លូវទឹកសាប បណ្តាញដឹកជញ្ជូនកម្ពុជា គឺធ្វើឡើងតាមទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ ដែលកប៉ាល់អាចធ្វើចរាចរណ៍បានលើផ្លូវទឹកប្រវែងសរុបប្រមាណជា ១,៧៥០ គ.ម នៅរដូវវស្សា ហើយអាចថយចុះមកត្រឹម ៥៨០ គ.ម នៅរដូវប្រាំង។ ភាពខុសគ្នានៃកំរិតទឹករវាងរដូវប្រាំង និងវស្សាពេលខ្លះកើនដល់ ១០ម៉ែត្រ។ ទោះបីជាការដឹកជញ្ជូនតាមផ្លូវទឹកសាបមានការកំណត់ព្រំដែនយ៉ាងដូច្នោះក្តី ក៏វិធានការនានា គួរតែត្រូវបានលើកមកអនុវត្តសំរាប់ធ្វើការស្តានីតិសម្បទា និងថែទាំប្រព័ន្ធទន្លេ ដើម្បីធ្វើឱ្យការដឹកជញ្ជូនតាមផ្លូវទឹកសាបមានប្រសិទ្ធភាពខ្ពស់ជាងនេះ។

ទាក់ទិននឹងធនធានទឹកសំរាប់ឧស្សាហកម្ម មានការលំបាកខ្លះក្នុងការទទួលបានទឹកដែលមានគុណភាពសំរាប់ប្រើប្រាស់ក្នុងឧស្សាហកម្មនៅតំបន់មួយចំនួនដែលតំបន់សេដ្ឋកិច្ចពិសេសកំពុងធ្វើការអភិវឌ្ឍន៍ ជាពិសេសនៅក្រុងព្រះសីហនុ។ ថ្វីបើទឹកក្រោមដី អាចត្រូវរាប់បញ្ចូលថាជាប្រភពផ្គត់ផ្គង់ប្រកបដោយស្ថេរភាពក៏ដោយ គុណភាពទឹកអាចមិនបំរើបាននូវតំរូវការចាំបាច់សំរាប់ឧស្សាហកម្មខ្លះ ដោយសារទឹកទាំងនោះអាចមានជាតិអំបិលក៏ថាបាន។ វិធានការនានា គួរតែត្រូវលើកមកធ្វើដើម្បីស្វែងរកឱ្យបាននូវប្រភពទឹកដែលគួរឱ្យទុកចិត្តបាន។ មធ្យោបាយមួយដើម្បីដោះស្រាយ បញ្ហានេះគឺត្រូវប្រើប្រាស់ទឹកពីស្ទឹងក្បាលឆាយ ហើយបង្ហូរតាមលូទឹកមកកាន់ទីក្រុងព្រះសីហនុ។ ទោះបីវាមានតម្លៃក៏ពិតមែនហើយ

ប៉ុន្តែវាមានតែមធ្យោបាយនេះទេ ដើម្បីទទួលបានទឹកគ្រប់គ្រាន់សំរាប់ឧស្សាហកម្មនៅក្នុងតំបន់ ប្រសិនបើ មានតំបន់ឧស្សាហកម្មធំៗត្រូវបានអភិវឌ្ឍន៍។

## ២.៣ បញ្ហានៃការចាត់ចែង

ក្នុងបរិការណ៍នៃបញ្ហានៃការចាត់ចែងនេះ វិធានការផ្សេងៗសំរាប់ការអភិវឌ្ឍន៍ការចាត់ចែងនិងពង្រឹងសមត្ថភាពជំរុញការវិនិយោគសំរាប់ ក.អ.ក/គ.វ.ក ត្រូវបានស្នើឡើង។ ជាពិសេស ការរៀបចំបណ្តុញការងារជំរុញការវិនិយោគជាមួយស្ថាប័ន និងទីផ្សារជប៉ុន សំរាប់ការជំរុញវិនិយោគ ដែលត្រូវតែយកចិត្តទុកដាក់ឱ្យបានខ្លាំង។ ការអភិវឌ្ឍន៍នៃសមត្ថភាពជំរុញការវិនិយោគនៃ ក.អ.ក/គ.វ.ក នឹងរួមវិភាគទានយ៉ាងធំធេងចំពោះការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា។

ក.អ.ក/គ.វ.ក បាននឹងកំពុងតែផ្តោតលើការកែលំអបរិស្ថានច្បាប់នៅកម្ពុជា ហើយគ្រប់មន្ត្រីរបស់ ក.អ.ក/គ.វ.ក ទាំងមានចំណេះដឹងផ្នែកច្បាប់នេះគ្រប់គ្រាន់។ ផ្ទុយទៅវិញ គេមានការពិបាកក្នុងការនិយាយថា ក.អក/គ.វ.ក មានប្រព័ន្ធនៃការចាត់ចែងការងារមួយស្របតាមការអនុវត្តន៍ជាក់ស្តែនូវបញ្ហាធុរកិច្ច ដោយរាប់បញ្ចូលទាំងការកំណត់នៃតំរូវការពីវិនិយោគិនផងដែរ។ ជាបន្តបន្ទាប់ មន្ត្រីក្នុង ក.អ.ក/គ.វ.ក នឹងទទួលបានប្រយោជន៍ពីការកើនឡើងនៃចំណេះដឹងធុរកិច្ចអនុវត្តជាក់ស្តែងមួយ។ គោលបំណងនៃផ្នែកនេះ គឺដើម្បីបង្កើតរចនាសម្ព័ន្ធនៃការចាត់ចែងការងារមួយប្រកបដោយប្រសិទ្ធភាព ចំពោះការរៀបចំពតិមានធុរកិច្ចសំរាប់វិនិយោគិន។

រចនាសម្ព័ន្ធសំខាន់ៗនៃផ្នែកនេះ ត្រូវបានរៀបរាប់ដូចខាងក្រោម:




## ២.៣.១ ការអភិវឌ្ឍន៍នៃការចាត់ចែងការងារ

ការអភិវឌ្ឍន៍នេះ អាចត្រូវបានចង្អុលបង្ហាញថាបញ្ហាប្រឈមនៃការចាត់ចែងការងារដ៏ធំបំផុតរបស់ ក.អ.ក/គ.វ.ក គឺជាភាពខ្សោយនៃកិច្ចសហប្រតិបត្តិការឆ្លងនាយកដ្ឋាន និងកង្វះខាតការចែករំលែកពតិមាន។ ជាពិសេស នាយកដ្ឋានផ្សេងគ្នា ចំណុះ ក.អ.ក/គ.វ.ក ដែលពាក់ព័ន្ធនឹងប្រតិបត្តិការនៃការត្រួតពិនិត្យ បានទុកពតិមានស្តីពីការត្រួតពិនិត្យនេះ

នៅនាយកដ្ឋានរៀងៗខ្លួន។ ដូច្នេះហើយ នាយកដ្ឋានទាំងអស់ ក្នុង ក.អ.ក/គ.វ.ក ចាំបាច់ត្រូវធ្វើសហប្រតិបត្តិការ និងចែករំលែកពត៌មានទាំងនោះ។ វិធានការដ៏មានសារៈសំខាន់សំរាប់ការអភិវឌ្ឍន៍ការចាត់ចែងការងារ គឺត្រូវបង្កើតកិច្ចសហប្រតិបត្តិការឆ្លងនាយកដ្ឋាន និងចែករំលែកពត៌មាន។ ជាបន្ថែម ការបង្កើតឱ្យមានបណ្ណាល័យផ្ទុកឯកសារ ជាប្រការចាំបាច់ដែលបានស្នើសុំក្នុងផែនការកំណែលំអរយៈពេលខ្លី សំរាប់ "សេវាកម្មអតិថិជន"។ សេវាកម្មក្នុងការរៀបចំចងក្រងពត៌មានត្រូវបានរំពឹងថានឹងមានប្រសិទ្ធភាព ដោយហេតុថាមានការលំបាកក្នុងប្រមូលពត៌មានវិនិយោគនៅកម្ពុជា។ ទាក់ទិននឹងប្រព័ន្ធបៀវត្សរ៍ក្នុង ក.អ.ក/គ.វ.ក ប្រព័ន្ធបៀវត្សរ៍ផ្អែកលើលទ្ធផលការងារ អាចត្រូវបានចាប់ផ្តើមប្រើ ដើម្បីនឹងលើកទឹកចិត្តដល់មន្ត្រីបំរើការងារ និងធ្វើឱ្យមានសកម្មភាពឡើងវិញនៅក្នុងអង្គភាពទាំងមូល។

**២.៣.២ ការជំរុញវិនិយោគ និងបណ្តាញពត៌មានវិនិយោគ**

ក្នុងបរិការណ៍នៃការជំរុញវិនិយោគ បញ្ហាប្រឈមមួយសំរាប់មន្ត្រី ក.អ.ក/គ.វ.ក គឺថាពួកគេគ្មានចំណេះដឹងទូលំទូលាយនៃភាពផ្សេងគ្នានៃផលិតផល ក្រុមហ៊ុន និងឧស្សាហកម្មនៅកម្ពុជា។ ដូច្នេះហើយ មន្ត្រីជំរុញការវិនិយោគ មានការលំបាកក្នុងការធ្វើផ្គូផ្គងប្រកបដោយប្រសិទ្ធភាពរវាងតំរូវការរបស់អ្នកផលិតក្នុងស្រុកនិងតំរូវការរបស់វិនិយោគិនបរទេស។ ក្នុងបរិការណ៍នេះ មន្ត្រីជំរុញការវិនិយោគ ត្រូវការផ្តល់ពត៌មានជូនវិនិយោគិនអនាគតមិនត្រឹមតែពត៌មានដែលបរិយាយពីបរិយាកាសវិនិយោគនោះទេ តែថែមទាំងពត៌មាននិយាយអំពីធុរកិច្ចលំអិតផងដែរ។ ការប្រមូលពត៌មាន ជាទូទៅ តំរូវឱ្យមានការប្រឹងប្រែងយ៉ាងខ្លាំងដែលត្រូវប្រើប្រាស់ពេលវេលាច្រើន។ ប៉ុន្តែ វាមានសារៈសំខាន់ចំពោះការកំណត់នូវសេចក្តីត្រូវការពីទីផ្សារក្នុងស្រុកដើម្បីពង្រឹងកាលានុវត្តន៍ភាពធុរៈកិច្ចក្នុងរង្វង់កម្ពុជាទាំងមូល។ ដូច្នេះបញ្ជីឈ្មោះនៃការជំរុញវិនិយោគដែលរាប់បញ្ចូលទាំងពត៌មានស្តីពីក្រុមហ៊ុន និងផលិតផល នឹងត្រូវបានស្នើសុំឡើង ដើម្បីនឹងប្រមូលនូវពត៌មានធុរៈកិច្ចពីគ្រប់ស្ថាប័នពាក់ព័ន្ធ និងធ្វើការផ្តល់ពត៌មានទាំងនេះចំពោះវិនិយោគិន។ ការប្រមូលពត៌មានប្រកបដោយប្រសិទ្ធភាព អាចត្រូវបានសំរេចទៅបានដោយមានការសហការពីសមាគមន៍ពាណិជ្ជកម្ម ដូចជាសភាពាណិជ្ជកម្មនៅកម្ពុជា។ សមាគមន៍ពាណិជ្ជកម្ម ជាទូទៅមានពត៌មានដែលមានតម្លៃស្តីពីក្រុមហ៊ុនក្នុងឧស្សាហកម្ម និងផ្នែកសំខាន់ៗពិសេសៗផ្សេងទៀត។ ការប្រមូលតាមវិធីនេះ អាចចាត់ទុកថាជាវិធីដ៏មានប្រសិទ្ធភាពបំផុតនៃការធ្វើបណ្តាញពត៌មានជាមួយសមាគមន៍ពាណិជ្ជកម្មទាំងនោះ ហើយមានតម្លៃសំរាប់ ក.អ.ក/គ.វ.ក។ ហេតុនេះ ការបង្កើតកិច្ចសហប្រតិបត្តិការជិតស្និទជាមួយសមាគមន៍ពាណិជ្ជកម្ម នឹងត្រូវបានផ្តល់ជាអនុសាសន៍។ មធ្យោបាយសំខាន់ដទៃទៀតនៃការជំរុញវិនិយោគ គឺរួមមាន ការអភិវឌ្ឍន៍វេបសៃត៍ និងការចេញផ្សាយប្រចាំខែនូវលិខិតពត៌មាន។

ក្នុងបរិការណ៍នៃបណ្តាញពត៌មានវិនិយោគ វិធានការផ្សេងៗ នឹងត្រូវបានស្នើឡើងជាបឋមសំរាប់ទីផ្សារជប៉ុន។ **ជាបឋម** គឺការបង្កើត "ក្រុមការងារជប៉ុន" នៅក្នុង ក.អ.ក/គ.វ.ក ដែលធ្វើការទំនាក់ទំនងដាច់ដោយឡែកជាមួយតែទីផ្សារជប៉ុន ក៏នឹងត្រូវបានស្នើឡើងជាអនុសាសន៍ដែរ។ ក្រុមហ៊ុនជប៉ុន ជាទូទៅពុំមានបទពិសោធន៍ (សូម្បីតែពត៌មាន)

ពីទីផ្សាររបស់កម្ពុជា ។ដូច្នេះ "ក្រុមការងារជប៉ុន" នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ទំនុកចិត្តចំពោះវិនិយោគិនជប៉ុន (ទំនុកចិត្តគឺជាតម្លៃរបស់ធុរៈកិច្ចសំខាន់បំផុតនៅជប៉ុន) ។ **ទីពីរ** ការធ្វើបណ្តាញពត៌មានវិនិយោគជាមួយស្ថាប័នពិសេស១ នៅជប៉ុន ក៏ត្រូវបានស្នើឡើងជាអនុសាសន៍ដែរ ។ ទាក់ទិនទៅនឹងការប្រមូលពត៌មាន វិនិយោគិនសក្តានុពលរបស់ជប៉ុន មានទំនោរទៅរកការទាក់ទងតាមមធ្យោបាយចំនួន ៥ ដូចតទៅ : (១) ស្ថាប័នរបស់រដ្ឋាភិបាល ដូចជា JICA និង JETRO (២) ក្រុមហ៊ុនពាណិជ្ជកម្មទូទៅ (៣) ក្រុមហ៊ុនផ្តល់សេវាទីប្រឹក្សា (៤) ស្ថាប័នអន្តរជាតិនៅជប៉ុន ដូចជា មជ្ឈមណ្ឌលអាស៊ាន-ជប៉ុន (៥) ផ្សេង១ ដោយរាប់បញ្ចូលទាំងសភាពាណិជ្ជកម្មផងដែរ ។ ដូច្នេះ វាហាក់បីដូចជាចាំបាច់ណាស់សំរាប់ ក.អ.ក/ គ.វ.ក ដើម្បីបង្កើតបណ្តាញពត៌មានជាមួយស្ថាប័នដែលបានរៀបរាប់រួចមកនេះ ។ **ទីបី** ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនៃសិក្ខាសាលា និងបេសកកម្មវិនិយោគ ដោយផ្តល់នូវពត៌មានមិនត្រឹមតែអំពីច្បាប់ប៉ុណ្ណោះទេ ថែមទាំងពត៌មានស្តីពីធុរកិច្ចផង ក៏ត្រូវបានស្នើឡើងជាអនុសាសន៍ដែរ ។ មធ្យោបាយសំខាន់ផ្សេងទៀត រាប់បញ្ចូលទាំងការរៀបចំឯកសារ និងសំភារៈជំរុញវិនិយោគជាភាសាជប៉ុន ព្រមទាំងចាត់តាំងមន្ត្រីពត៌មានសំរាប់ទីផ្សារជប៉ុនផងដែរ ។ ជាបន្ថែមលើនេះ ការបង្កើតការិយាល័យតំណាងនៅជប៉ុន ដែលហៅថា "តុជប៉ុន (Japan Desk)" ត្រូវបានរំពឹងថានឹងដើរតួនាទីយ៉ាងសំខាន់នាពេលអនាគត ។ គោលបំណងនៃការបង្កើត "តុជប៉ុន" នេះ គឺដើម្បីដឹកនាំការលក់នៃសំណើវិនិយោគទៅដល់ក្រុមហ៊ុនជប៉ុន ផ្តល់សេវាទីប្រឹក្សាចំពោះក្រុមហ៊ុនជប៉ុន រៀបចំសិក្ខាសាលាវិនិយោគ ប្រមូលពត៌មានទីផ្សារ និងផ្តល់សេវាកម្មសំរាប់ដាក់ពាក្យស៊ីវិនិយោគជូនវិនិយោគិន ។ **ជាចុងបញ្ចប់នេះ** វាមានសារៈសំខាន់ណាស់ចំពោះ ក.អ.ក/គ.វ.ក ដើម្បីប្រើប្រាស់វិធានការដែលបានស្នើឡើងខាងលើ (ដោយធ្វើប្រតិបត្តិការប្រហាក់ប្រហែលគ្នានេះ) សំរាប់ប្រទេសដទៃទៀតនៅអាស៊ីនេះ ។

### ២.៣.៣ កាលវិភាគនៃការអនុវត្តន៍នូវការស្នើឡើងជាអនុសាសន៍

ក្នុងផ្នែកនេះ ការស្នើឡើងជាអនុសាសន៍ចំនួន ១៤ ជុំវិញការអភិវឌ្ឍន៍ការចាត់ចែងការងារ និងការជំរុញវិនិយោគត្រូវបានស្នើឡើងសំរាប់អភិវឌ្ឍន៍សមត្ថភាពរបស់ ក.អ.ក/គ.វ.ក ។ កាលវិភាគនៃការអនុវត្តន៍សំរាប់វិធានការដែលបានស្នើឡើងជាអនុសាសន៍ទាំង ១៤ នឹងត្រូវបង្ហាញជូនក្នុងតារាងដូចខាងក្រោម:

**តារាងទី ១ កាលវិភាគនៃការអនុវត្តន៍នូការស្នើឡើងជាអនុសាសន៍ សំរាប់ ក.អ.ក/គ.វ.ក**

| អនុសាសន៍ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | - | ២០២០ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **ការអភិវឌ្ឍន៍របៀបចាត់ចែងការងារ** | | | | | | | | | | | | |
| បណ្ណាល័យឯកសារ | | | | | | | | | | | | |
| ការចែករំលែកពត៌មាន | | | | | | | | | | | | |
| ប្រព័ន្ធបៀវត្សរ៍ផ្អែកលើលទ្ធផលការងារ | | | | | | | | | | | | |
| **ការជំរុញវិនិយោគ** | | | | | | | | | | | | |
| បញ្ជីឈ្មោះការជំរុញវិនិយោគ | | | | | | | | | | | | |

## របាយការណ៍បញ្ចប់

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| កិច្ចសហប្រតិបត្តិការជាមួយសមាគមពាណិជ្ជកម្ម | ■ | | | | | | | | | | | |
| លិខិតសារពត៌មាន | ■ | ■ | | | | | | | | | | |
| វេបសៃត៍ | ■ | ■ | | | | | | | | | | |
| **បណ្តាញពត៌មាន** | | | | | | | | | | | | |
| "ក្រុមការងារជប៉ុន" | ■ | ■ | ■ | ■ | | | | | | | | |
| រៀបចំបណ្តាញជាមួយស្ថាប័នជប៉ុន | ■ | ■ | | | | | | | | | | |
| មន្ត្រីគ្រប់គ្រងពត៌មាន | ■ | | | | | | | | | | | |
| សំភារៈផ្សព្វផ្សាយ | ■ | ■ | | | | | | | | | | |
| បេសកកម្មវិនិយោគ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| សិក្ខាសាលាវិនិយោគ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| "តុជប៉ុន" | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |

ក្នុងការស្នើឡើងជាអនុសាសន៍ទាំង ១៤ ខាងលើ អនុសាសន៍ទាំងនេះ នឹងត្រូវបានធ្វើអាទិភាពរូបនីយកម្មក្នុងទិដ្ឋភាពអនាគត ជា ការសំខាន់ ការប្រញាប់ និងប្រត្យក្សកម្ម សំរាប់សមត្ថភាពជំរុញការវិនិយោគនៅ ក.អ.ក/គ.វ.ក។ អាទិភាពខ្ពស់បំផុត ត្រូវបានជ្រើសរើស ក្នុងគោលបំណងដើម្បីទទួលបាននូវពត៌មានវិនិយោគ ជាពិសេសពត៌មានធុរកិច្ចនៅក្នុង ក.អ.ក/គ.វ.ក។ វិធានការទាំងនេះ រាប់បញ្ចូលទាំងការពង្រឹងនៃការចែករំលែកពត៌មានក្នុង ក.អ.ក/គ.វ.ក ធ្វើបញ្ជីឈ្មោះនៃការជំរុញវិនិយោគ និងបង្កើតបណ្តាញសហប្រតិបត្តិការជិតស្និទជាមួយសមាគមពាណិជ្ជកម្ម។

អាទិភាពទីពីរ ត្រូវបានផ្តល់ចំពោះវិធានការដែល : (១) មានដំណើការនាបច្ចុប្បន្ន ដូចជាការអភិវឌ្ឍន៍វេបសៃត៍ ព្រមទាំងបេសកកម្ម និងសិក្ខាសាលាវិនិយោគ និង (២) មានគោលបំណងដើម្បីបង្កើនសមត្ថភាពសំរាប់ចែកចាយពត៌មាន រាប់បញ្ចូលទាំង ការបង្កើតបណ្ណាល័យឯកសារ ការចេញផ្សាយលិខិតសារពត៌មានប្រចាំខែ ការរៀបចំ "ក្រុមការងារជប៉ុន" ធ្វើសំភារៈផ្សព្វផ្សាយវិនិយោគ រៀបចំបណ្តាញជាមួយស្ថាប័នជប៉ុន និងចាត់តាំងមន្ត្រីគ្រប់គ្រងពត៌មាន។

ជាចុងបញ្ចប់ ការបង្កើតឡើងនូវ "តុជប៉ុន" មានអាទិភាពទី ៣។ "តុជប៉ុន" នេះ នឹងជាសារៈសំខាន់ណាស់សំរាប់ការអភិវឌ្ឍន៍នាពេលអនាគតនូវសមត្ថភាពជំរុញការវិនិយោគ ប៉ុន្តែ ប្រត្យក្សកម្មរបស់វា ហាក់បីដូចជាមានការលំបាកដោយសារតែថវិការបស់ ក.អ.ក/គ.វ.ក នៅមានកំរិតកំណត់នៅឡើយក្នុងបច្ចុប្បន្នកាល។ "តុជប៉ុន" នេះ គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពបំផុត ពេលដែលសញ្ញាណនៃការវិនិយោគនៅកម្ពុជា ត្រូវបានទទួលការពេញនិយមក្នុងចំណោមវិនិយោគិនជប៉ុននាពេលអនាគត។ ជាបន្ថែម ការចាប់ផ្តើមនៃប្រព័ន្ធបៀវត្សរ៍ផ្អែកលើលទ្ធផលការងារ តំរូវឱ្យមានការពិនិត្យពិចារណាឱ្យបានដិតដល់បំផុតសំរាប់ការអនុវត្តន៍របស់ប្រព័ន្ធនេះ។

តារាងទី ៣ អាទិភាពសំរាប់ការស្នើឡើងជាអនុសាសន៍

| **អាទិភាព** | **ការស្នើឡើងជាវិធានការ** |
|---|---|

| | |
|---|---|
| អាទិភាពខ្ពស់បំផុត | ការអភិវឌ្ឍន៍ការចាត់ចែងការងារ : *ការចែករំលែកពត៌មាន*<br>ការជំរុញវិនិយោគ : *បញ្ជីនៃការជំរុញវិនិយោគ និងកិច្ចសហប្រតិបត្តិការជាមួយសមាគមន៍ពាណិជ្ជកម្ម* |
| អាទិភាពខ្ពស់ | ការអភិវឌ្ឍន៍ការចាត់ចែងការងារ : *បណ្ណាល័យឯកសារ*<br>ការជំរុញវិនិយោគ : *"លិខិតសារពត៌មាន" "វ៉ែបសៃត៍" "ក្រុមការងារជប៉ុន" "សំភារៈផ្សព្វផ្សាយ" "បេសកកម្ម និងសិក្ខាសាលាវិនិយោគ" "ការធ្វើបណ្តាញជាមួយស្ថាប័នជប៉ុន" និង "ការចាត់តាំងមន្ត្រីគ្រប់គ្រប់ពត៌មាន"* |
| អាទិភាពទាប | ការអភិវឌ្ឍន៍ការចាត់ចែងការងារ : *ប្រព័ន្ធបៀវត្សរ៍ដែលផ្អែកលើលទ្ធផលនៃការងារ*<br>ការជំរុញវិនិយោគ : *តុជប៉ុន* |

## ២.៤ ផែនការសកម្មភាព និងគំរោងការនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច

ផ្នែកនេះ មានសង្ខេបពីបញ្ហាក្នុងការទាក់ទាញការវិនិយោគបរទេសផ្ទាល់មកកម្ពុជា ធ្វើសំណើសំរាប់ការកែលំអក្នុងឧស្សាហកម្មសន្សាទីមួយៗ និងអភិវឌ្ឍន៍គម្រោងការនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចសំរាប់ ក.អ.ក/គ.វ.ក ។ ការតំរូវឱ្យមានការកែលំអ ត្រូវបានស្នើឡើងសំរាប់វិស័យនីមួយៗនោះ ត្រូវបានចាត់ប្រភេទ ដោយផ្អែកលើប្រភេទធំៗទាំងបីដូចខាងក្រោម :

- កំណែលំអសំរាប់ការទាក់ទាញការវិនិយោគបរទេសផ្ទាល់
- កំណែលំអសំរាប់ការអភិវឌ្ឍន៍ឧស្សាហកម្ម
- កំណែលំសំរាប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ

ពេលនោះ សំណើសំរាប់ផែនការសកម្មភាពក្នុងបរិវេណនៃយុទ្ធសាស្ត្ររបស់ការវិនិយោគបរទេសផ្ទាល់ ត្រូវបានធ្វើ ។ សំណើទាំងនោះ រួមមាន :

- ផែនការសកម្មភាពសំរាប់ការអភិវឌ្ឍន៍ការចាត់ចែងការងារ ក្នុង ក.អ.ក/គ.វ.ក
- ផែនការសកម្មភាពសំរាប់ការជំរុញវិនិយោគក្នុង ក.អ.ក/គ.វ.ក ដែលរាប់បញ្ចូលទាំងការរៀបចំបញ្ជីនៃការជំរុញវិនិយោគ ការបង្កើតកិច្ចសហប្រតិបត្តិការជាមួយសមាគមន៍ពាណិជ្ជកម្ម និងសភាពាណិជ្ជកម្ម ព្រមទាំងការរៀបចំសិក្ខាសាលាវិនិយោគ
- ការផ្តល់សិទ្ធិ និងកំណែលំអនៃភ្នាក់ងារអធិការកិច្ច និងលក្ខណៈវិនិច្ឆ័យសំរាប់វាយតម្លៃម្ហូបអាហារ
- បង្កើតហេដ្ឋារចនាសម្ព័ន្ធឃ្លាំងទំនិញក្នុងសីតុណ្ហភាពទាប ឃ្លាំងទំនិញត្រជាក់ និងឃ្លាំងបង្កក ព្រមទាំងប្រព័ន្ធដឹកជញ្ជូនត្រជាក់ និងបង្កក

- ផែនការសកម្មភាពសំរាប់ការអភិវឌ្ឍន៍នៃឧស្សាហកម្មកែច្នៃម្ហូបអាហារដែលរាប់បញ្ចូលទាំងការពង្រឹងសហករណ៍នេសាទ និងកសិកម្ម ដើម្បីធានាបាននូវការផ្គត់ផ្គង់សំភារៈឋិតថេរ ព្រមទាំងពង្រឹងការជំរុញវិនិយោគ

រចនាសម្ព័ន្ធសំខាន់នៃផ្នែកនេះ រាប់បញ្ចូល :




### ២.៤.១ គម្រោងការនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច

របាយការណ៍នេះ បានស្នើនូវគម្រោងការនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចសំរាប់ដៃគូរនៃការសិក្សានេះ គឺ ក.អ.ក/គ.វ.ក។ វា ជាការចាំបាច់ដើម្បីអនុវត្តមធ្យោបាយប្រកបដោយប្រសិទ្ធភាពនៃគម្រោងការនៃកិច្ចសហប្រតិបត្តិការ ដែលពង្រឹង ក.អ.ក/គ.វ.ក ដើម្បីជំរុញការវិនិយោគបរទេសចូលក្នុងឧស្សាហកម្មសក្តានុពលទាំង ៥ របស់កម្ពុជា។ ការអភិវឌ្ឍន៍សមត្ថភាពជំរុញការវិនិយោគ ក៏ដូចជាការអភិវឌ្ឍន៍បច្ចេកវិទ្យាពតិមានសំរាប់ ក.អ.ក/គ.វ.ក នឹងត្រូវបានស្នើជាអនុសាសន៍នៅក្នុងគម្រោងការនៃជំនួយបច្ចេកទេសនេះដែរ។ ទាក់ទិនទៅនឹងគម្រោងការ នៃការអភិវឌ្ឍន៍សមត្ថភាពរបស់ការជំរុញវិនិយោគនេះ កាលវិភាគនៃការអនុវត្តន៍ ត្រូវបានស្នើចេញជាពីរដំណាក់កាល។ គោលបំណងនៃដំណាក់កាលទី ១ គឺដើម្បីបង្កើតរចនាសម្ព័ន្ធចាត់ចែងការងារជាមូលដ្ឋានសំរាប់ការជំរុញវិនិយោគក្នុង ក.អ.ក/គ.វ.ក។ គោលបំណងនៃដំណាលទី ២ គឺដើម្បីពង្រឹង សមត្ថភាពនៃការជំរុញវិនិយោគក្នុង ក.អ.ក/គ.វ.ក។ ជាបន្ថែមលើនេះ គម្រោងការនៃ ជំនួយបច្ចេកទេសសំរាប់ការអភិវឌ្ឍន៍បច្ចេកវិទ្យាពតិមាន ត្រូវបានស្នើឡើងផងដែរ ដើម្បីនឹងពង្រឹងកិច្ចសហប្រតិបត្តិការឆ្លងនាយកដ្ឋានក្នុង ក.អ.ក/គ.វ.ក និងការចែករំលែកពតិមានរវាងនាយកដ្ឋាន ក្នុង ក.អ.ក/គ.វ.ក។